ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី២ ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក
ស
វ



ECOSOCC

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

## គតិបណ្ឌិតបិតាស្ថាបនិកសន្តិភាពកម្ពុជា

« ប្រជាជនកម្ពុជាត្រូវចងចាំក្នុងចិត្តថា គណបក្សប្រជាជនកម្ពុជា
គឺជានិមិត្តរូបនៃការផ្លាស់ប្តូរពិតប្រាកដនៅកម្ពុជា »

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
១៦ មីនា ២០២៣

# មាតិកា

**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- ឃឹម ណុលសន

និពន្ធនាយក

- អ៊ីវ ថុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ អាននូដាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា
- អ៊ិន តុលា

អ្នកចែកផ្សាយ

- អៀង រដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង វត្តមុនី
- សយ វាស្នា
- ឃឹម ច័ន្ទតារា

**ទំព័រ**

I- បទអត្ថាធិប្បាយ ការបែកបាក់ក្រុងលង្វែក និងផលវិបាក ១-១០

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រាអនុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ១១-១២

២- សេចក្តីព្រាងអនុក្រឹត្យស្តីពីលក្ខណវិនិច្ឆ័យ នៃមន្ទីរពិសោធន៍យោង និងមន្ទីរពិសោធន៍ផ្លូវការ ១៣

III- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣ ១៤-២៣

IV- បទវិភាគៈ

១- គំនិតនៃសង្គ្រាមត្រជាក់ ២៤

២- រូបិយប័ណ្ណ BRICS ២៤

៣- ស្ត្រីខ្មែរ កំពុងបោះជំហានចូលទីផ្សារឌីជីថលយ៉ាងរស់រវើក ២៥

V- នាទីសិក្សា-ស្រាវជ្រាវ

- ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផលនៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦ (ត) ២៦-៣០

VI- នាទីវប្បធម៌

១- ពន្យល់ពាក្យ ៣១

២- ស្វែងយល់ពី ទំនោរធម្មជាតិមនុស្ស (Tendance de la nature humaine) ៣២-៣៣

VII- នាទីកំណាព្យ

១- ឱ ! នេះឬមេផ្ទះ (បទពាក្យ៧) ៣៤

២- ចំណូលចិត្ត (បទពាក្យ៧) ៣៤

VIII- នាទីកំសាន្ត

១- ល្បើកដើមទៀបនិងដើមសេដា ៣៥

២- ល្បើកឆ្មានិងកណ្តុរ ៣៥

# ការបែកបាក់ក្រុងលង្វែក និងផលវិបាក

## I- សង្ខេបប្រវត្តិ

### ១. ព្រះបាទសត្ថាទី១ (១៥៧៦-១៥៩៥)

ក្រោយពីព្រះបិតា(បរមរាជាទី៤) សោយទីវង្គតទៅ ព្រះរាជបុត្រច្បងនាម សត្ថា ឡើងសោយរាជ្យស្នងដោយមាននាមសម្រាប់រាជ្យថា ព្រះបាទសម្ដេចព្រះបរមរាជាធិរាជរាមាធិបតី។ អ្នកប្រវត្តិសាស្ត្រនិយម ហៅស្ដេចអង្គនេះថា ព្រះសត្ថាទី១ ឬ ព្រះបរមរាជាទី៥។ព្រះអង្គទ្រង់អភិសេកអ្នកម្នាងពៅជាអគ្គមហេសី នាម សម្ដេចព្រះភគវតីស្រីចក្រពត្តិរាជ និងអភិសេកព្រះអនុជបន្ទាប់នាម ស្រីសុរិយោពណ៌ជាមហាឧបរាជ។កាលគ.ស.១៥៧៤បានសម្ពពនឹងអគ្គមហេសីនូវបុត្រនាមព្រះជ័យជេដ្ឋាហើយកាលសោយរាជ្យបាន៤ឆ្នាំ (១៥៨០) បានសម្ពពរាជបុត្រមួយអង្គទៀតនាម ចៅពញាតន់។ ព្រះអង្គមានម្នាងលាវមួយទៀតឈ្មោះអ្នកម្នាងពេជម៉ែលាវហើយបានសម្ពពនឹងអ្នកម្នាងនេះនូវបុត្រនាម ចៅពញាញោម។ ឯព្រះអនុជមានព្រះរាជបុត្រពីរអង្គនាម ព្រះជ័យចេស្ដា ១អង្គ ព្រះឧទ័យ ១អង្គ។

#### ១.១. ទំនាក់ទំនងជាមួយសៀម

បើតាមឯកសារសៀមថាព្រះសត្ថាបានលើកទ័ពចូលវាយក្រុងពេជ្របុរី ចំនួនបីដង គឺចន្លោះគ.ស. ១៥៧៤ ដល់ ១៥៨០។ ទីបំផុតចូលវាយមឿងពេជ្របុរី ហើយបានបោសសម្អាតមនុស្សយកទៅទៀត។ ឯកសារសៀមថាដូច្នេះព្រោះបានចាត់ទុកថាព្រះបរមរាជាទី៤បានសោយទីវង្គតតាំងពីគ.ស.១៥៧៤។ បើតាមរាជពង្សាវតារខ្មែរខ្លះថា ព្រះសត្ថា ទ្រង់បានលើកទ័ពទៅវាយក្រុងអយុធ្យា ចាប់បានឈ្លើយសឹកសៀមជាច្រើនទំនងជាក្នុងគ.ស.១៥៧៩ឬ១៥៨៩០។ក្បួនរាជពង្សាវតារខ្លះទៀតនិយាយថា នៅគ.ស. ១៥៨០ នោះប្រទេសសៀមនៅជាចំណុះរបស់ស្ដេចភូមានាម បាយិន ណោង នៅឡើយ។ ព្រះរាជបុត្រស្ដេចសៀមនាម នរេសួរ (នរេស្វរៈ) បានទៅនៅបម្រើស្ដេចភូមានៅក្រុង ហង្សាវតី។ ថ្ងៃមួយ នរេសួរ បានលើកដៃថ្វាយបង្គំស្ដេចភូមា ហើយស្ដេចភូមាទ្រង់ទតឃើញមានព្រះហស្តបួន ទ្រង់ជ្រាបថា ជាអ្នកមានបុណ្យ ក៏រកលេសសម្លាប់។នរេសួរដឹងខ្លួនរត់មកក្រុងអយុធ្យាវិញ ហើយពួកភូមាដេញតាម។ ព្រះចៅសៀមទ្រង់ផ្ញើសារមកសុំជំនួយពីខ្មែរ។ ដោយទ្រង់គោរពតាមសន្ធិសញ្ញាសន្តិភាពខ្មែរ-សៀមកាលពីគ.ស.១៥៧៤ ព្រះបាទ សត្ថាទី១ ទ្រង់បញ្ជាឱ្យមហាឧបរាជ ស្រីសុរិយោពណ៌លើកទ័ពទៅជួយតាមសំណូមពរ។ទ័ពខ្មែរបានជួយច្បាំងព្រះនរេសួររហូតបានជ័យជំនះលើភូមា។លុះលើកទ័ពមកវិញព្រះនរេសួរទ្រង់ទតឃើញព្រះ ស្រីសុរិយោពណ៌ គង់សំយុងព្រះបាទ ពុំបានគង់ក្រាបដូចអ្នកផង ក៏ទ្រង់ព្រះពិរោធណាស់។ ម៉្យាងទៀតព្រះនរេសួរទ្រង់បានកែនរាស្ត្រក្នុងខេត្តដែលត្រូវឡើងមកស្ដេចខ្មែរ។ ព្រះស្រីសុរិយោពណ៌ ទ្រង់ខ្វាល់ពីរឿងនេះខ្លាំងណាស់ហើយលើកទ័ពត្រឡប់ចូលនគរវិញ។ចំពោះរឿងនេះមានឯកសារខ្លះបានសរសេរថា «ប៉ុន្តែជ័យជំនះនេះពុំបានធ្វើឱ្យសៀមអបអរសាទរឡើយ ផ្ទុយទៅវិញ ជ័យជំនះនេះបណ្ដាលឱ្យអាប់កិត្តិយសកងទ័ពសៀមហើយជាពិសេសអាប់កិត្តិយសរបស់រាជបុត្រ ស្ដេចសៀម នាម ព្រះនរេសួរ។ ចាប់តាំងពីពេលនោះមកព្រះនរេសួរតែងមានគំនុំចង់យកស្រុកខ្មែរ ជាចំណុះដោយរំលោភលើកិច្ចចរចាក្នុងឆ្នាំ១៥៧៦។គួរគប្បីជ្រាបថាចំពោះជំនួយទ័ពរបស់ខ្មែរខាងលើនេះ ឯកសារសៀមពុំមាននិយាយទេ។

តាមប្រភពយុនបរមវិសេសៈ ហ្លួងរតនៈសម្បត្តិ បានឱ្យដឹងដូច្នេះថា ដោយរងការឈ្លានពានពីសំណាក់នគរហង្សាវតី (ភូមា) យ៉ាងខ្លាំង ហើយ

ដោយមើលឃើញពីសមត្ថភាពកងទ័ពដ៏អង់ អាចក្លាហានរបស់លង្វែកក្រោមព្រះបញ្ញាញាណវែងឆ្ងាយរបស់ព្រះមហាក្សត្រខ្មែរ ព្រះបាទបរមរាជាទី៤ (រាជ្យគ.ស.១៥៦៦-៧៦) ដែលបានលើកទ័ពទៅសង្កត់ឡោមព័ទ្ធក្រុងស្រីអយុធ្យា៣លើក ក្នុងគ.ស. ១៥៧០ ១៥៧២ និង១៥៧៤ និងបានដឹងថាខ្មែរបានឈ្នះសង្គ្រាមលាវ ដោយប្រើទ័ពតិចយកឈ្នះលើទ័ពដ៏ច្រើនរបស់នគរលានដំរីស្រីនាគតនហ៊ុតផង (លាវឈ្លានពានក្រោយមិនគោរពពាក្យសច្ចៈក្នុងការភ្នាល់ជល់ ដំរី ដាក់តំណាំងនគរ ក្នុងគ.ស.១៥៧២ ព្រះពញាសេដ្ឋាធិរាជបានលើកទ័ពមកទាំងពីរច្រកជើងគោក១សែននាក់និងដំរីសេះជាច្រើនពាន់ក្បាលនិងទ័ពជើងទឹក៥ម៉ឺននាក់តាមដងទន្លេមេគង្គ)។ សៀមក្នុងរាជ្យព្រះបាទមហាធម្មរាជា(គ.ស.១៥៦៨ -៨៩)ត្រូវជាព្រះបិតារបស់ព្រះបាទនរេសូរ(១៥៨៩ -១៦០៤)បានយល់ព្រមបង្កើតសន្ធិសញ្ញាមេត្រីភាពក្នុងគ.ស.១៥៧៦ នៅអាងសិលា។ សេចក្តីសំខាន់នៃសន្ធិសញ្ញាជារួមមាន៖

«១.នគរទាំងពីរប្តេជ្ញាចងសម្ព័ន្ធមេត្រីភាពជាមួយគ្នាជាបងប្អូន ហើយមិនមានការឈ្លានពានគ្នាតទៅទៀតឡើយ។

២.សៀមត្រូវព្រមប្រគល់មហាខេត្តខ្មែរទាំងបីរួមមាន ច័ន្ទបុរី បស្ទិមបុរី និងនគររាជសីមា ដែលធ្លាប់វាយយកមកគ្រប់គ្រង ឱ្យស្ថិតក្នុងដែនដីរបស់កម្ពុជាវិញ។

៣.នគរទាំងពីរនឹងត្រូវជួយគ្នាទៅវិញទៅមកប្រសិនបើមានការឈ្លានពានពីសត្រូវខាងក្រៅ។»

លេសរំលោយសន្ធិសញ្ញាមេត្រីភាពខ្មែរ-សៀម :

ក្រោយពីខ្មែរបានគ្រប់គ្រងលើមហាខេត្តទាំងបីវិញ នគរទាំងពីរបានរស់នៅជាសុខសាន្ត មិនមានការឈ្លាពានគ្នាទៅវិញទៅមកឡើយ។ លុះដល់គ.ស. ១៥៨៥ នគរហង្សាវតី ដោយមានក្តីព្រួយបារម្ភពីការរីកចម្រើនរបស់នគរស្រីអយុធ្យា និងការចង់ប្រកាសឯករាជ្យចេញពីចំណុះហង្សាវតី របស់សៀមផង ភូមាក៏បានសម្រេចចិត្តលើកទ័ព២៥ម៉ឺននាក់មកវាយក្រុងស្រីអយុធ្យា។ ដោយខ្មែរ-សៀម មានសន្ធិសញ្ញាសម្ព័ន្ធមេត្រីផង ខាងលង្វែកក្នុងរាជ្យព្រះសត្ថាទី១ ឬព្រះបរមរាជាទី៥(១៥៧៦-៨៦)ក៏បានចេញព្រះរាជបញ្ជាឱ្យព្រះបាទស្រីសុរិយោពណ៌ ដែលជាព្រះមហាឧបរាជ បានរៀបចំកងទ័ពចំនួន ២ម៉ឺននាក់ ទៅជួយក្រុងស្រីអយុធ្យា។

តាមការស្រាវជ្រាវប្រវត្តិសាស្ត្រជាតិនិយមរបស់សៀម បានអះអាងថា ការធ្វើសឹកសង្គ្រាមលើកនេះសៀមមិនបានឃើញការជួយច្បាំងពីកងទ័ពលង្វែកតាមសមគួរទេ គេឃើញតែកងទ័ពលង្វែកជាកងទ័ពជួរក្រោយ ហើយចាំប្រមូលតែជ័យភណ្ឌប៉ុណ្ណោះ ពួកមេទ័ពសៀមមានការមិនពេញចិត្តយ៉ាងខ្លាំង។ ព្រះបាទនរេសូរ បានយល់ឃើញថា ការធ្វើសឹកលើកនេះនឹងអាចឈ្នះហង្សាវតីដោយមិនចាំបាច់មានការជួយពីកងទ័ពលង្វែកឡើយ ប៉ុន្តែបើដេញកងទ័ពលង្វែកទៅវិញក្រែងខុសព្រះរាជបវេណី ដែលព្រះបិតាបានចងសម្ព័ន្ធមេត្រីភាពយូរមកហើយ។ ពួកមេទ័ពសៀមទាំងឡាយក៏គិតរកឧបាយ ដើម្បីដេញព្រះបាទសុរិយោពណ៌ ត្រឡប់ទៅនគរវិញ ។

ដំបូងពួកមេទ័ពសៀមបានបង្ខំឱ្យព្រះបាទស្រីសុរិយោពណ៌ថ្វាយបង្គំ ព្រះបាទនរេសូរ ក្នុងឋានៈជានគរតូចជាង បើទោះជាមានសក្តិជាព្រះមហាឧបរាជដូចគ្នាក៏ដោយ។ ព្រះបាទស្រីសុរិយោពណ៌មិនព្រមដោយលើកហេតុផលថាជាត្រកូលក្សត្រដូចគ្នាហើយព្រះអង្គថ្វាយបង្គំតែព្រះមហាក្សត្រខ្មែរតែប៉ុណ្ណោះ។

លើកក្រោយទៀត ពួកមេទ័ពសៀម បានយកក្បាលខ្មោចទាហានភូមាទៅដោតតម្រៀបនៅកំពង់ទូកព្រះទីនាំងរបស់ព្រះបាទស្រីសុរិយោពណ៌ព្រះអង្គបានខ្ញាល់យ៉ាងខ្លាំង ដោយចាត់ទុកជាការមើលងាយព្រះចេស្តា ហើយក៏បានឈានដល់មានការឈ្លោះប្រកែកជាមួយព្រះនរេសូររហូតសម្រេចចិត្តដកកងទ័ព

លង្វែកត្រឡប់មកនគរវិញ។ ព្រះបាទនរេសូរក៏បាន ប្រកាសថា « ការដកទ័ពថយរបស់ក្រុងលង្វែក ជាការបំពានសន្ធិសញ្ញាសម្ព័ន្ធមេត្រីភាពរវាងនគរទាំងពីរ » ហើយចាត់ទុកជាប្រយោជន៍ ដើម្បីឈ្លានពានកម្ពុជាឡើងវិញ ។

ព្រះបាទសត្ថាព្រះអង្គបានខ្វាល់ និងងឿងឆ្ងល់ជាមួយព្រះបាទស្រីសុរិយោពណ៌ ពីការដកទ័ពមកវិញទាំងការសឹកមិនទាន់បានបញ្ចប់ប៉ុន្តែក្រោយពីបានស្តាប់យល់ដំណើរសេចក្តីហើយ ព្រះអង្គក៏លាន់ព្រះឱស្ឋថា៖«សៀមចង់បំពានមើលងាយព្រះចេស្តាក្រុងលង្វែកហើយអំណឹះតទៅពួកសៀមនឹងជាសត្រូវរបស់ក្រុងលង្វែក »។

នៅគ.ស.១៥៨១ ខ្មែរបានលើកទ័ពទៅវាយរំដោះបាននគររាជសីមា ចន្ទបុរី និង នគរនាយក។ ឯកសារសៀមថា សម្តេចព្រះនរេសូរ បានលើកទ័ពទៅតស៊ូ។ ឯកសារខ្មែរថា ព្រះនរេសូរវាយយកបាននគររាជសីមាវិញ នៅគ.ស.១៥៨២ គឺស្របនឹងឯកសារសៀមដែរ តែឯកសារសៀមមិនបានបញ្ជាក់ថា យកបានខេត្តណាទេ ។ឯកសារសៀមនិយាយថា កាលសម្តេចព្រះនរេសូរប្រកាសឯករាជ្យរំដោះប្រទេសសៀមពីចំណុះភូមា(គ.ស.១៥៨៤) ទ្រង់មានកិត្តិសព្ទល្បីល្បាញ ព្រះសត្ថាក្រែងថា សៀមនឹងត្រឡប់មកសងសឹកកម្ពុជាទើបតែងព្រះរាជសារមេត្រីសារភាពទទួលខុស ព្រមចំណុះក្រុងស្រីអយុធ្យា។ ត្រង់ចំណុចនេះ ឯកសារខ្មែរពុំបាននិយាយដល់ទេ។ យើងគ្រាន់តែឆ្ងល់ថា តើការពិតស្ថិតនៅត្រង់ណា បើកាលណោះ ខ្មែរអាចជួយសៀមច្បាំងឈ្នះភូមាថែមទៀត ហេតុដូចម្តេចក៏ត្រឡប់ជាខ្លាចសៀមវិញ។ គួរគប្បីជ្រាបថា នៅប្រទេសភូមាឯណោះ ស្តេចនាមនន្ទា បាយិន(Nanda Bayin) បានឡើងសោយរាជ្យស្នងព្រះបិតានាម បាយិន ណោង (Bayin Naung) ពីគ.ស.១៥៨១ដល់១៥៩៩។ស្តេចអង្គនេះជាស្តេចមានមហិច្ឆតា ទ្រង់បានបន្តនយោបាយវាតយកទឹកដីរបស់ព្រះបិតាព្រះអង្គ។ ដោយហេតុនោះហើយ បានជានៅគ.ស.១៥៨៥ ព្រះអង្គបានលើកទ័ពចូលវាយក្រុងអយុធ្យាម្តងទៀត។ ឯកសារសៀមថា ព្រះសត្ថាជឿថា ក្រុងអយុធ្យាគង់នឹងបាត់បង់ដោយភូមាដូចគ្រាមុន ទ្រង់បានផ្តាច់មេត្រីភាព ហើយលើកទ័ពចូលវាយស្រុកបស្ចិមបុរី។ត្រង់នេះឯកសារខ្មែរថា ទ័ពខ្មែរយកបាន បស្ចិមបុរី នគររាជ និងនគរនាយក។ លុះសៀមលើកទ័ពមក ខ្មែរក៏ថយសិន ហើយដោយមានដំណឹងថា សម្តេចព្រះភគវតី ប្រឈួន ព្រះសត្ថាក៏លើកទ័ពត្រឡប់មកបន្ទាយលង្វែកវិញ។ ឯកសារសៀមបាននិយាយថា«សម្តេចព្រះនរេសូរទ្រង់ខ្វាល់នឹងព្រះសត្ថា ដូចនេះក្នុងគ.ស.១៥៨៦ កាលភូមាលើកទ័ពត្រឡប់ទៅវិញហើយទើបស្តេចលើកទ័ពទៅវាយក្រុងកម្ពុជា ហើយវាយបានស្រុកបាត់ដំបង និងស្រុកពោធិ៍សាត់រួចក៏លើកទ័ពត្រឡប់មកព្រះនគរវិញព្រោះខ្វះស្បៀងអាហារ»។ ត្រង់នេះ ឯកសារខ្មែរខ្លះនិយាយថា «សៀមក៏ចាប់ធ្វើសង្គ្រាមទន្ទ្រានទឹកដីខ្មែរដោយគ្មានលេសអ្វីឡើយ»។ឯក្សួនរាជពង្សាវតារខ្មែរខ្លះបាននិយាយថា នៅគ.ស.១៥៨៤ (គ.ស.១៥៨៦ សមជាង ព្រោះនៅពេលនោះ ភូមាដកថយទៅវិញហើយ) ព្រះនរេសូរ លើកទ័ពមកវាយខ្មែរ ខ្មែរបានលើកទ័ពទៅប្រយុទ្ធគ្នាយ៉ាងខ្លាំងនៅបាត់ដំបងរួចបន្តទៅស្ទឹងកំពង់ប្រាក់តែដោយសារទន់ដៃជាងក៏ដកថយសិន។ សៀមវាយយកបានបន្ទាយមានជ័យរួចយកបានបន្ទាយបរិបណ៌ទៀត។ ព្រះស្រីសុរិយោពណ៌ នាំទ័ពថយចូលក្នុងបន្ទាយលង្វែក។ រាជពង្សាវតារខ្មែរខ្លះបញ្ជាក់ថាក្នុងចម្បាំងលើកនោះសៀមមានទ័ពចំនួន ១០០ ០០០នាក់ ដំរីចំនួន ៨០០ និងសេះចំនួន១៨៥០។ទោះបីមានទ័ពច្រើនសន្ធឹកសន្ធាប់និងខ្លាំងពូកែយ៉ាងនេះក៏ដោយក៏សៀមពុំអាចវាយលុកយកបានបន្ទាយលង្វែកឡើយ។ក្រោយពីឡោមព័ទ្ធបន្ទាយនេះអស់រយៈពេល៣ខែ ដោយខ្វះស្បៀងអាហារ និងដោយត្រូវជំងឺឆ្លងរាតត្បាតស្លាប់អស់ច្រើនផងសៀម

ក៏ដកទ័ពថយទៅវិញ ព្រោះខ្មែរដឹងចំណុចខ្សោយរបស់សៀម ហើយនាំគ្នាចេញពីបន្ទាយទៅវាយលុកយ៉ាងខ្លាំង។

ប្រវត្តិវិទូខ្លះថា មានកងទ័ពខ្មែរមួយមកពីក្រៅជួយធ្វើអន្តរាគមន៍កំចាត់សៀមទៅវិញ។ឯកសារខ្មែរខ្លះនិយាយថាទ័ពសៀមឈឺស្លាប់ច្រើនគឺបណ្តាលមកពីបិសាចធ្វើ។ ព្រះនរេសូរ បានចាត់ឱ្យសាកសួរខ្មែរក៏បានដឹងថា មានទេវរក្ស ១៣អង្គ ជួយថែរក្សានគរខ្មែរ។ ម្យ៉ាងទៀត មុននឹងរត់ដកខ្លួនទៅ សៀមបានប្រើឧបាយកលបាញ់ប្រាក់ដួងជាច្រើនចូលក្នុងគុម្ពឫស្សី ដែលជារបងយ៉ាងមាំមួនជាទីបំផុតសម្រាប់ការពារបន្ទាយលង្វែក។ ក្រោយមក ព្រះចៅសៀមបានចាត់ចារបុរសពីនាក់ចូលមកធ្វើវិទ្ធង្សនានិងបង្កើតឱ្យមានចលាចលក្នុងផ្ទៃក្នុងរបស់ខ្មែរ ហើយមហាតលិកសៀមពីនាក់ បានក្លែងខ្លួនធ្វើជាអ្នកបួស នាមតិបញ្ញោ និង សុប្បញ្ញោ មកធ្វើពិធីដកសិល្បសាស្ត្រដែលបញ្ចុះក្នុងរូបទេវរក្ស។ សុប្បញ្ញោ ប្រើមន្តអាគមធ្វើឱ្យអ្នកស្រុកឈឺ ហើយតិបញ្ញោធ្វើជាអ្នកដោះឱ្យជាសះស្បើយវិញ។

នៅប្រមាណជាគ.ស.១៥៨៦ ព្រះបាទ សត្ថាទី១ ទ្រង់សព្វព្រះរាជហឫទ័យ ដាក់រាជ្យថ្វាយទៅព្រះរាជបុត្រច្បង នាមព្រះ ជ័យជេដ្ឋា ដែលមានព្រះជន្មទើប ១១វស្សា ឱ្យឡើងសោយរាជ្យស្នងពីព្រះអង្គ ដោយមានព្រះនាមសម្រាប់រាជ្យថា ព្រះបាទសម្តេចព្រះរាជឱង្ការ ជ័យជេដ្ឋាធិរាជរាមាធិបតី។ ព្រះរាជបុត្រទី២ ចៅពញាតន់ ដែលមានព្រះជន្មទើប ៦វស្សា ត្រូវបានតាំងឱ្យឡើងជាឧបរាជ។ ឯព្រះស្រីសុរិយោពណ៌ ត្រូវបានឡើងជាឧភយោរាជ។ ដោយព្រះរាជបុត្រសុទ្ធតែនៅក្មេងៗពេក កិច្ចការគ្រប់គ្រងរដ្ឋ គឺស្ថិតនៅក្នុងកណ្តាប់ព្រះហស្តព្រះសត្ថាទាំងអស់។ ត្រង់នេះ មានសំនួរចោទឡើងថា បើព្រះអង្គនៅតែកាន់អំណាចដដែល ដូច្នេះហេតុអ្វីក៏ចាំដាក់រាជ្យថ្វាយទៅព្រះរាជបុត្រ? អ្នកប្រវត្តិសាស្ត្រខ្លះបានឱ្យយោបល់ថាហេតុដែលនាំឱ្យព្រះសត្ថាទ្រង់ប្រព្រឹត្តដូច្នេះ ព្រោះព្រះអង្គខ្លាចក្រែងរាជសម្បត្តិ ពុំបានទៅព្រះរាជបុត្រ តែបានទៅព្រះស្រីសុរិយោពណ៌វិញ នៅពេលដែលព្រះអង្គសោយទិវង្គត ព្រោះព្រះអនុជនេះជាស្តេចមានសមត្ថភាពហើយត្រូវបានប្រជារាស្ត្រភាគច្រើន គោរពស្រឡាញ់រាប់អានទៀតផង។

ឯកសារខ្មែរបានបញ្ជាក់ថា អំពើរបស់ព្រះសត្ថាខាងលើនេះ បានបណ្តាលឱ្យមានការអាក់អន់ស្រពន់ចិត្តជាច្រើន ពីសំណាក់រាជវង្សានុវង្ស នាម៉ឺនសព្វមុខមន្ត្រីនិងអាណាប្រជានុរាស្ត្រ។ ចោរលួចចោរប្លន់ក៏កើតឡើងព្រោងព្រាត។ រីឯប្រជារាស្ត្រខ្មែរកាលបើដឹងថា គ្រាប់ដែលសៀមបាញ់ចូលក្នុងរបងគុម្ពឫស្សីជាប្រាក់សុទ្ធ ក៏មានចិត្តត្រេកអរពន់ពេកនាំគ្នាកាប់ឆ្ការព្រៃឫស្សីដើម្បីយកប្រាក់នោះ ទោះបីមានបំរាមពីព្រះរាជាយ៉ាងណាក៏ពុំព្រមស្តាប់ ហើយចេះតែនាំគ្នាប្រព្រឹត្តអំពើនោះរហូតដល់ធ្លុះធ្លាយរបងឫស្សីអស់។

នៅគ.ស.១៥៩៣ សៀមបានលើកទ័ពវាយចូលបន្ទាយលង្វែកជាថ្មីម្តងទៀត។ ព្រះ នរេសូរ បានបញ្ជាឱ្យទ័ពចូលជា៣ផ្លូវ។ខ្មែរលើកទ័ពចេញទៅតទល់តែលើកនេះក៏ដូចជាលើកមុន សៀមវាយ យកបានជាបន្តបន្ទាប់ នូវបន្ទាយពោធិ៍សាត់ និងបន្ទាយបរិបូណ៌។ ព្រះឧភយោរាជស្រីសុរិយោពណ៌ បកសំបុត្រទៅឱ្យកែនទ័ព ប្រមូលស្បៀងចូលការពារក្នុងបន្ទាយលង្វែក។ ទ័ពដែលចេញទៅទប់ខាងនគរវត្តក៏ទប់ពុំជាប់។ ឯខាងជើងទឹកក៏ចាញ់សៀមទៀត។ សៀមវាយកាន់តែខ្លាំងឡើង ព្រះឧភយោរាជ ថយមកនៅបន្ទាយរលៀប្អៀរ ហើយសុំជំនួយពីលង្វែក។ សៀមក៏លើកទ័ពមកព័ទ្ធបន្ទាយទៀត។លុះទ័ពសៀមមកជិតដល់ ព្រះសត្ថាទី១ នាំបុត្រនាមជ័យជេដ្ឋា និងចៅពញាតន់ គៀសទៅគង់នៅស្រីសន្ធរ ក្រោយមកទៀតគៀសទៅស្ទឹងត្រែងហើយនៅទីបំផុតគៀសទៅគង់នៅវៀងចាន់ ជារាជធានីប្រទេសលាវ។

ចំណែកឯព្រះស្រីសុរិយោពណ៌ បានស្ថិតនៅក្នុងបន្ទាយលង្វែកដើម្បីប្រយុទ្ធនឹងខ្មាំង។ តែទោះបីព្រះអង្គបានខិតខំការពារបន្ទាយយ៉ាងណាក៏ដោយក៏បន្ទាយនេះត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃខ្មាំង ក្រោយពីត្រូវឡោមព័ទ្ធអស់រយៈពេល៣ខែ ព្រោះវាបានយកចំបើងដុតរបងឫស្សី ដែលនៅសល់បន្តិចបន្តួចនោះនៅគ.ស.១៥៩៣។ សៀមចាប់បានព្រះឧភយោរាជស្រីសុរិយោពណ៌ និងបុត្រទាំងពីរ គឺព្រះជ័យចេស្ដា (ព្រះជន្ម១៥វស្សា) និងព្រះឧទ័យ (ព្រះជន្ម៥វស្សា) នាំយកទៅប្រទេសសៀម ព្រមជាមួយនឹងក្បួនខ្នាតអ្នកប្រាជ្ញបណ្ឌិតកវីរូបបដិមាព្រះគោព្រះកែវនិងឈ្លើយខ្មែរជាច្រើនទៀត ។

ក្រោយពីបានស្នាក់នៅក្នុងប្រទេសខ្មែរអស់ពេល៣ខែមក ព្រះនរេសូរ បានយាងត្រឡប់ទៅក្រុងអយុធ្យាវិញទុកឱ្យតែមហាមន្ត្រីសៀមនៅឈរនៅក្រុងឧដុង្គ។គួរគប្បីជ្រាបថានៅខាងមុខព្រះវិហារព្រះកែវនៅទីក្រុងបាងកកប្រទេសថៃសព្វថ្ងៃ មានរូបបដិមាព្រះគោដែលមានទំហំសឹងប៉ុនសត្វគោធំពោះប្រហោងក្នុង។ តើនេះជានិមិត្តរូប ព្រះគោព្រះកែវ ដែលសៀមបាននាំយកទៅនៅគ្រាដែលវាយបែកបន្ទាយលង្វែកឬយ៉ាងណា?ចំពោះចម្បាំងរវាងខ្មែរ-សៀមនៅគ.ស. ១៥៩៣នេះ ឯកសារសៀមបាននិយាយថា មកតែពីខ្មែរមិនរក្សាពាក្យសច្ចៈ ទើបព្រះនរេសូរលើកទ័ពមកសងសឹក។ សម្ដេចព្រះនរេសូរ ឃើញកម្លាំងកម្ពុជាទន់ខ្សោយ ទើបមានតម្រាស់ឱ្យព្រះសត្ថា មកគាល់តែព្រះសត្ថាត្រឡប់ជាចាប់ទូតថៃ ដែលអញ្ជើញ ព្រះបរម រាជឱង្ការ ឃុំទុក ហើយក៏បញ្ជូនទ័ពតស៊ូយ៉ាងខ្លាំង។ ម្យ៉ាងទៀត រាជពង្សាវតារសៀម បានអះអាងថា ទ័ពសៀមបានចាប់បានទាំងព្រះមហាក្សត្រខ្មែរ ហើយព្រះចៅសៀមទ្រង់បញ្ជាឱ្យប្រហារជីវិតព្រះអង្គដើម្បីយកព្រះលោហិតទៅលាងព្រះបាទទៀតផង។ សព្វថ្ងៃនេះ នៅវត្ត យ៉េជ័យមង្គល នាខេត្តអយុធ្យាគេឃើញមានរូបគំនូរ២ផ្ទាំងដែលគួរឱ្យចាប់អារម្មណ៍រូបទី១ជារូបស្ដេចខ្មែរគង់អង្គុយលើកៅអីមួយទាបមានព្រះសុរង ព្រះបាទ និងព្រះហស្ដជាប់ចំណង និងច្រវាក់។ រូបទី២ បង្ហាញពីបុរសម្នាក់ស្លៀកពាក់សកំពុងតែលុតជង្គង់ យកលោហិតស្ដេចខ្មែរទៅលាងព្រះបាទឱ្យស្ដេចសៀម ។ តើរឿងនេះជាការពិត ឬក៏ជារឿងប្រឌិត សម្រាប់តែលើកសរសើរពីមហិទ្ធិរិទ្ធព្រះចៅសៀមនាសម័យនោះ? រាជពង្សាវតារខ្មែរគ្រប់ក្បួនទាំងអស់ពុំឃើញមាននិយាយពីព្រឹត្តិការណ៍នេះឡើយ ។

### ១.២. ទំនាក់ទំនងជាមួយអឺរ៉ុប

បើតាមប្រភពអឺរ៉ុប ព្រះសត្ថា ជាក្សត្រទន់ខ្សោយ ហើយទ្រង់មានព្រះហឫទ័យ ច្រណែនចំពោះព្រះអនុជ គឺព្រះស្រីសុរិយោពណ៌។ ដោយហេតុថាព្រះអង្គត្រូវការជំនួយដើម្បីប្រឆាំងនឹងសត្រូវខាងក្នុងនិងខាងក្រៅព្រះអង្គក៏ទ្រង់បានយកចិត្តពួកអ្នកផ្សាយសាសនាយ៉ាងខ្លាំង។ពួកនេះមានសិទ្ធិពេញលេញក្នុងការផ្សាយលទ្ធិរបស់ខ្លួន មានសិទ្ធិសង់ព្រះវិហារនៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រ។ព្រះរាជាទ្រង់បានជួយឧបត្ថម្ភពួកនេះ រហូតដល់បានបញ្ជូនអង្ករនិងវត្ថុផ្សេងៗទៀតទៅឱ្យអង្គការដូមីនីកាំងនៅ Malaca ។

នៅគ.ស.១៥៨៥ នាយចៅហ្វាយរបស់បព្វជិត Sylvestre បានសម្រេចចិត្តថាត្រូវតែគាំទ្រលោក ហើយបានបញ្ជូននូវបព្វជិតពីរអង្គទៀតគឺ បព្វជិត Antonio Dorta និងបព្វជិត Antonio Caldeira ។ ក្នុងពេលដំណាលគ្នានោះ មានបព្វជិតខាងគណៈហ្វ្រង់ស៊ីស្កាំង (Franciscain) ក៏បានមកប្រទេសខ្មែរដែរ ក្នុងចំណោមនេះ មានបព្វជិតនាម Gregorio Ruiz ។ តែដោយមានការធ្វើទុក្ខបុកម្នេញកើតឡើងជាថ្មីទៀត បព្វជិតទាំងពីរអង្គខាងក្រោយនេះក៏និមន្តត្រឡប់ទៅវិញអស់។ ពេលនោះ បព្វជិត ស៊ីលវែសបានប្រើឥទ្ធិពលរបស់លោក ហើយព្រះសត្ថាទី១ ក៏ទ្រង់អនុញ្ញាតនៅគ.ស.១៥៨៩ថា បព្វជិតអង្គណាក៏ដោយ អាចផ្សាយសាសនាបាននៅគ្រប់ទីកន្លែងក្នុង

ប្រទេសខ្មែរ ហើយជនជាតិខ្មែរណាក៏ដោយ ក៏អាចកាន់សាសនាថ្មីនេះបានដោយគ្មានខ្លាចពីការសងសឹកឡើយ។ ដោយហេតុនោះបព្វជិតស៊ីលវែសក៏បានសុំឱ្យអង្គការកណ្ដាលបញ្ជូនបព្វជិតមកជាបន្ថែម។ ជាការឆ្លើយតបនឹងសេចក្ដីអំពាវនាវនេះ បព្វជិតហ្សកដឺម៉ូតា ( Jorge de Mota ) និង ល្វី ដឺ ហ្វុងសេកា ( Luis de Fonseca ) ក៏ត្រូវបានគេបញ្ជូនមកទៀត តែនៅពេលនោះ លោកទាំងពីរនិមន្តមកដល់ បព្វជិត ស៊ីលវែស ក៏បានសុគតរួចទៅហើយ ។

គួរគប្បីជ្រាបថា នៅគ្រានោះមិនគ្រាន់តែមានពួកបព្វជិតទេ ដែលបានមកប្រទេសខ្មែរ ពួកអ្នកផ្សងព្រេងខ្លះក៏បានមកក្នុងពេលជាមួយគ្នាដែរ ។នៅគ.ស.១៥៨៥ ជនជាតិព័រទុយក័ល ដែលមានវ័យនៅក្មេង( ២០ឆ្នាំ ) ឈ្មោះ ឌីយោគោ វេឡូសូ ( Diogo Veloso )បានមកដល់ប្រទេសខ្មែរជាមួយបក្សពួកមួយក្រុមគឺ Carneiro, Machado, Sagredo, Diogo de chaves Carnizares...។ ប៉ុន្មានឆ្នាំក្រោយមកទៀត ( ដើមគ.ស.១៥៩៣ ) អ្នកផ្សងព្រេងជាតិអេស្ប៉ាញក៏បានមកដល់ គឺលោក រី ដឺ ហ៊ែណង់ គង់សាឡេស ( Ruiz de Hernan Gonzalès )និងវ៉ាហ្គាស ម៉ាស៊ូកា ( Vargas Machuca ) ។

ពួកជនផ្សងព្រេងទាំងនេះត្រូវបានព្រះ សត្ថាស្រឡាញ់រាប់អានយ៉ាងខ្លាំង ហើយពួកនេះក៏ជាប់ជំពាក់ចិត្តយ៉ាងខ្លាំងជាមួយនិងព្រះអង្គវិញដែរ ។ព្រះសត្ថា ទ្រង់សព្វព្រះទ័យរៀបអភិសេក ប្អូនជីដូនមួយស្រីម្នាក់របស់ព្រះអង្គ ឱ្យទៅលោក ឌីយោគោ វេឡូសូងចំណែកលោករីវិញត្រូវបានព្រះអង្គតែងតាំងជាអង្គរក្សរបស់ព្រអង្គ។

យើងឃើញថានៅគ.ស.១៥៩៣ ព្រះចៅសៀមនាមព្រះនរេសូរបានលើកទ័ពចូលមកវាយខ្មែរជាលើកទី២ ដោយមានរេហ៍ពលច្រើនជាងលើកទី១ទៅទៀត។ តាមរយៈ វេឡូសូ ព្រះសត្ថាទី១ ទ្រង់បានទាក់ទងជាមួយអ្នកកាន់អំណាចព័រទុយក័ល នៅម៉ាឡាកា( Malaca )ពួកព័រទុយក័លមិនអាចជួយខ្មែរព្រោះរវល់ជាប់ដៃច្បាំងនឹងពួក ម៉ាឡាយូ នៅអាសេះ ( Acheh ) និងនៅ ជហ៏រ ( Johore )។ ដោយហេតុដូចនោះ ទើបព្រះសត្ថាទី១ ទ្រង់ងាកទៅរកជំនួយពីពួកអេស្ប៉ាញវិញតាមការថ្វាយយោបល់របស់លោករី និង វ៉ាហ្គាស។

គួរគប្បីជ្រាបថាជនជាតិអេស្ប៉ាញជាជនជាតិអឺរ៉ុប ដែលបានមកកាន់អាស៊ីអគ្នេយ៍ បន្ទាប់ពី ពួកព័រទុយក័ល។ ពួកនេះបានវាយប្រទេសហ្វីលីពីន ដាក់ជាអាណានិគមរបស់ខ្លួន ក្នុងរាជ្យស្ដេច ហ្វីលីពទី២ ( Philippe II ) ហើយការវាយប្រទេសហ្វីលីពីននេះជាស្នាដៃរបស់មេទ័ពជើងទឹកម្នាក់ឈ្មោះ Miguel Lopez de Legaspi ។ ពួកអេស្ប៉ាញបានត្រួតត្រាប្រទេសហ្វីលីពីនពីគ.ស.១៥២៧ដល់គ.ស.១៨៩៦ ហើយបានតាំងរាជធានីរបស់ខ្លួននៅក្រុងម៉ានីល។

នៅខែកក្កដា ១៥៩៣ ព្រះសត្ថាទី១ ទ្រង់ចាត់ឱ្យលោក វេឡូសូ មួយអន្លើនិង វ៉ាហ្គាស និង ការណេរ៉ូ ( Carneiro ) នាំយកព្រះរាជសារទៅជូនលោកទេសាភិបាលអេស្ប៉ាញនៅក្រុងម៉ានីលដើម្បីសុំជំនួយទ័ពមកច្បាំងនឹងសៀម។ ដើម្បីជាសគុណ ព្រះអង្គទ្រង់បានសន្យាថា នឹងបើកសិទ្ធិឱ្យពួកអេស្ប៉ាញ មកផ្សាយសាសនានិងធ្វើជំនួញនៅប្រទេសខ្មែរ។លោកទេសាភិបាលអេស្ប៉ាញ ឈ្មោះ គោម៉េ ប៉េរ៉េ ដាសម៉ារីណាស់ ( Gomez Perez Dasmarinas ) បានសរសេរលិខិតចុះថ្ងៃទី២៧ ខែកញ្ញា ១៥៩៣ ឆ្លើយតបមកព្រះរាជាខ្មែរវិញថានឹងជួយផ្សះផ្សាជម្លោះរវាងខ្មែរនិងសៀម។លោកពុំបានបញ្ជូនជំនួយទ័ពមកជួយខ្មែរទេព្រោះលោកកំពុងតែរៀបចំទៅវាយយកកោះម៉ូលុក ( Moluques )។ ជាអកុសល នៅពេលដែលចេញដំណើរនៅថ្ងៃទី៣០ ខែកញ្ញា ១៥៩៣ លោកត្រូវពួកចិនអ្នកអុំសំពៅលោក លួចធ្វើឃាតលោកទៅ។

កូនប្រុសលោកឈ្មោះ ល្វី ប៉េរ៉េ ដាសម៉ារីណាស់ ( Luis Perez Dasmarinas ) បានឡើងកាន់

អំណាចជំនួសឪពុកលោក។ លោកទេសាភិបាលថ្មីនេះ បានសរសេរលិខិតមួយទៀតផ្ញើទៅ ថ្វាយព្រះរាជាខ្មែរ។វេឡូសូនិងបក្សពួកបានសំបុត្រនោះហើយក៏ធ្វើដំណើរត្រឡប់មកប្រទេសខ្មែរវិញ។ជាអកុសលទ័ពសៀម បានវាយលុកយកបានបន្ទាយលង្វែកជាស្រេច ។

វេឡូសូ និង ការណេរ៉ូ បានធ្វើសង្គ្រាមវាយឆ្មក់ប្រឆាំងជាមួយនឹងពួកសៀម តែត្រូវគេចាប់បានហើយយកទៅឃុំឃាំងជាមួយនិងរី( Ruiz )ជាអ្នកនៅការពារបន្ទាយលង្វែកជាមួយនិងព្រះឧភយោរាជស្រីសុរិយោពណ៌ ។ ក្រៅពីនេះ មានបព្វជិតជាតិអឺរ៉ុបខ្លះទៀតត្រូវសៀមចាប់យកទៅក្រុងអយុធ្យាដែរ គឺបព្វជិត ហ្សក ដឺ ម៉ូតា និង ល្វី ដឺ ហ្វុងសេកា ។

ពួកឈ្លើយសង្គ្រាមទាំងនោះ ខ្លះត្រូវបានដឹកនាំទៅតាមផ្លូវគោក ខ្លះទៀតទៅតាមផ្លូវទឹក ។ លោករី ការណេរ៉ូ និង ម៉ាសាដូ ត្រូវគេដឹកទៅតាមសំពៅមួយ ។ លោករី បាននាំពួកឈ្លើយសឹកបះបោរ ឡើងដណ្តើមយកបានសំពៅហើយធ្វើដំណើរឆ្ពោះទៅក្រុងម៉ានីល( ទៅដល់នៅខែមិថុនា ១៥៩៤ )។

ចំណែកលោក វេឡូសូ នៅក្រុងអយុធ្យា ត្រូវបានព្រះនរេសួរចាត់ឱ្យនាំរាជទូតសៀម ទៅក្រុងម៉ានីលដើម្បីសុំចងសម្ព័ន្ធមេត្រីជាមួយពួកអេស្ប៉ាញនៅគ.ស.១៥៩៥។ លុះសំពៅមកដល់ច្រកទន្លេមេណាម គេក៏បានដំណឹងតាមទាហានសៀមដែលបានបាក់ទ័ពពីលង្វែកថាស្តេចខ្មែរដណ្តើមអំណាចបានវិញហើយ។លោកវេឡូសូរមិនដឹងថាព្រះរាមជើងព្រៃស្មានថាព្រះសត្ថា ។លោកក៏បន្តដំណើរទៅដល់ក្រុងម៉ានីលនៅពាក់កណ្តាលខែមិថុនា១៥៩៥ហើយបានជួបនឹងមិត្តរបស់លោកគឺ រី ការណេរ៉ូ និង ម៉ាសាដូ។

ដូច្នេះត្រង់ដែលត្រូវការពារផលប្រយោជន៍របស់សៀម លោក វេឡូសូរ មានគំនិតចង់ត្រឡប់មកជួយខ្មែរវិញ។ ដោយសារហេតុនោះ លោកបានស្រុះស្រួលជាមួយមិត្តភក្តិលោកធ្វើអន្តរាគមន៍សុំជំនួយពីពួកអេស្ប៉ាញ ដើម្បីមកជួយព្រះរាជាខ្មែរ ហើយបានទទួលការគាំទ្រយ៉ាងសកម្ម ជាពិសេសពីសំណាក់លោកទេសាភិបាល ល្វី ប៉េរ៉េ ដាសម៉ារីណាស់ ។

## II- ផលវិបាកនៃការបែកបាក់ក្រុងលង្វែក

ការវាយបែកក្រុងលង្វែកដោយជនជាតិសៀមមានផលវិបាកអាក្រក់យ៉ាងខ្លាំង សម្រាប់ប្រជាជាតិខ្មែរ។ តពីនេះទៅទៀត ខ្មែរត្រូវពើបប្រទះនឹងវិបត្តិកាន់តែច្រើនឡើង។ យ៉ាងណាមិញ ទំនាស់ផ្ទៃក្នុងបូករួមជាមួយនិងកត្តាផ្សេងៗដទៃទៀត បានញ៉ាំងមហាអំណាចខ្មែរអង្គរ ឱ្យចុះទន់ខ្សោយបន្តិចម្តងៗរហូតដល់លើករាជធានី ពីយសោធរបុរមកតាំងនៅទួលបាសានរួចនៅចតុមុខ។ នៅសម័យលង្វែក ជាពិសេសក្នុងរជ្ជកាលរបស់ព្រះអង្គចន្ទរាជានិងព្រះបរមរាជាទី៤ខ្មែរបានពង្រឹងជំហររបស់ខ្លួនបានវិញហើយមានលទ្ធភាពលើកទ័ពទៅវាយលុករាជធានីស្រីអយុធ្យា និងវាយរំដោះយកអាណាខេត្តខាងលិចមកវិញបានជាច្រើន។ ប៉ុន្តែ ក្រោយពីបន្ទាយលង្វែកត្រូវបែកបាក់ទៅ ទឹកដីមួយភាគធំនៅឯនាយភ្នំដងរែក និងនៅខាងលិចត្រូវបាត់បង់ទៅវិញជាស្ថាពរ។

### ១. ការជ្រែករាជ្យនៃព្រះរាមជើងព្រៃ( ១៥៩៤ - ១៥៩៦ )

ព្រះរាមជើងព្រៃត្រូវជាព្រះញាតិរបស់ព្រះសត្ថាទី១ ។ នៅគ.ស.១៥៩៤ ព្រះអង្គបានលើកទ័ពទៅវាយសៀមនៅបន្ទាយឧដុង្គ។ សៀមចាញ់ ក៏ដកថយទៅស្រុកវិញអស់ទៅ។ ព្រះរាមជើងព្រៃ (តាមឯកសារព័រទុយក័លហៅថា Anacaparan )បានឡើងសោយរាជ្យនៅស្រីសន្ធរ( siri strol ឬ Sistor ) ។

រួចហើយមកទៀត យើងបានឃើញថា លោកវេឡូសូរ កាលដែលទៅសុំជំនួយពី ទេសាភិបាលអេស្ប៉ាញ នៅប្រទេសហ្វីលីពីន បម្រុងយកមកជួយព្រះសត្ថាទី១ នោះ ឃើញថាបានទទួលការគាំទ្រយ៉ាងសកម្ម ជាពិសេសពីសំណាក់លោកទេសាភិបាល ល្វី ប៉េរ៉េ ដាសម៉ារីណាស់ តែម្តង ។

បើតាមឯកសារអឺរ៉ុប លោក វេឡូសូរ បាន ធ្វើបញ្ជីតាមតម្រូវការ ហើយបានដាក់ជូនទៅលោកទេសាភិបាល ។ ក្នុងបញ្ជីនោះ មានគ្រោងតាំងពីការតាំងអាណាព្យាបាលភាពរបស់អេស្ប៉ាញ មកលើប្រទេសខ្មែរ និងការផ្លាស់សាសនារបស់ប្រជារាស្ត្រខ្មែរទាំងស្រុង។ កងនាវាបានចេញដំណើរ ពីក្រុងម៉ានីល នៅថ្ងៃទី១៩មករា១៥៩៦ ហើយត្រូវស្ថិតនៅក្រោមបញ្ជាការរបស់មេទ័ពឈ្មោះហ្សូរ៉េសកាល្លីណាតូ(Jaurez Gallinato) : ពលទាហានមានប្រមាណពី១២០ ទៅ ១៣០នាក់ ជនជាតិជប៉ុនកាន់ សាសនាគ្រិស្ត២០នាក់ជនជាតិហ្វិលីពីនខ្លះនិងបព្វជិតគណៈដូមីនីកាំង៣អង្គ ។ មេពួកបព្វជិតគណៈ ដូមីនីកាំង គឺបព្វជិត Alonso Jimenez ជាសហាមេបញ្ជាការនៃប្រតិបត្តិការនេះ ។

លុះធ្វើដំណើរមកដល់ក្រុងចតុមុខ (churdu muco) លោក វី និងលោក វេឡូសូរ ទើបភ្ញាក់ខ្លួនដឹងថាព្រះសត្ថាទី១(Apran Langara) និងព្រះរាជបុត្រ២អង្គបានភៀសទៅប្រទេសលាវហើយហើយមានក្សត្រថ្មីឡើងសោយរាជ្យរួចស្រេចដែរ។ នៅថ្ងៃ ទី១២ មេសា១៥៩៦ជម្លោះមួយបានផ្ទុះឡើងរវាងពួកឈ្មួញចិន និងពួកទាហានជើងទឹកអេស្ប៉ាញ ។ ឈ្មួញចិនប្រមាណ១០០នាក់ត្រូវស្លាប់ ហើយទំនិញនិងសំពៅរបស់ខ្លួនក៏ត្រូវរឹបអូសទាំងអស់។លោកវេឡូសូរ បានសុំអនុញ្ញាតពីព្រះរាមជើងព្រៃ ឱ្យចូលគាល់ដើម្បីបំភ្លឺព្រះអង្គពីឧប្បត្តិហេតុដែលបានកើតឡើងនោះ។ តែព្រះរាជាដាក់លក្ខខណ្ឌថាទាល់តែពួកអេស្ប៉ាញព្រមសងទំនិញទៅពួកចិនទាំងអស់ជាមុនសិន ទើបព្រះអង្គទ្រង់អនុញ្ញាតឱ្យបាន។ ដោយហេតុនោះ លោក វេឡូសូរ និងលោក វី បានសម្រេចថាត្រូវតែប្រើកម្លាំងទ័ពវិញ ជាមួយនិងទាហាន ៣៨នាក់ គេបាននាំគ្នាទៅឡោមព័ទ្ធវាំងនៅស្រីសន្ធរទាំងយប់ ដើម្បីធ្វើគត់ព្រះរាមជើងព្រៃ បានមុនពេលថ្ងៃរះ (ឯកសារខ្លះថា នៅម៉ោង២ល្ងាច) រួចវិលត្រឡប់មកក្រុងភ្នំពេញ ហើយបានជួបនឹងកងនាវារបស់លោក Callinato ដែលត្រូវខ្យល់បក់រុញច្រានរហូតទៅដល់សិង្ហបុរី និងត្រូវសំចតនៅ ឡាម៉ាកា ដើម្បីធ្វើការជួសជុលខ្លះ។ លោក Callinato មិនពេញចិត្តចំពោះសកម្មភាពរបស់ទាហានលោក។លោកថែមទាំងបានបង្ខំឱ្យទាហានសងទំនិញដែលបានប្លន់យកពីឈ្មួញចិន ហើយក្រោយពីបានធ្វើការពិនិត្យឱ្យស្គាល់ទឹកដីបន្តិចបន្តួច ក៏បានចេញដំណើរឆ្ពោះទៅប្រទេសចាម្ប៉ា ទោះបីមានការប្រឆាំងតវ៉ាពីសំណាក់លោក វេឡូសូរនិងពួកបព្វជិតយ៉ាងណាក៏ដោយ។លោកបានចូលសំចតនៅ Cachan (Faifo) ដើម្បីឱ្យលោកវី និងលោកវេឡូសូរធ្វើដំណើរទៅវៀងចាន់នាំយកពត៌មានទៅថ្វាយព្រះសត្ថាទី១ ស្ដីពីហេតុការណ៍នៅក្នុងប្រទេសខ្មែរ ។ ក្រុមនាវិករបស់លោក Callinato មានជម្លោះជាមួយឈ្មួញជប៉ុន និងជនជាតិយួននៅលើឆ្នេរសមុទ្រ ហើយដោយខ្លាចរដូវភ្លៀងមកដល់ លោកក៏ចេញដំណើរទៅកាន់ក្រុងម៉ានីលវិញ នៅដំណាច់ គ.ស.១៥៩៦។

## ២.ព្រះបរមរាជាទី៦ ចៅពញាតន់(១៥៨៦-១៥៩៩)

លុះទៅដល់ក្រុងវៀងចាន់ដោយបានឆ្លងកាត់តាមជួរភ្នំអណ្ណាមមក លោក វី និង វេឡូសូរ មានសេចក្តីសោកស្តាយយ៉ាងខ្លាំងដោយដឹងថា ព្រះសត្ថាទី១និងព្រះរាជបុត្រច្បងគឺជ័យជេដ្ឋាបានសោយទីវង្គតរួចទៅហើយ។ លោកទាំងពីរក៏បានដង្ហែព្រះរាជបុត្របន្ទាប់គឺ ចៅពញាតន់ រាជវង្សានុវង្ស និងទាហានលាវខ្លះឱ្យត្រឡប់ចូលមកប្រទេសខ្មែរវិញ ។ នៅតាមផ្លូវ គេបានជួបប្រទះនឹងកងទ័ពជើងទឹកមួយដែលស្ថិតនៅក្រោមបញ្ជាការរបស់ជ្វាម្នាក់ដែលព្រះរាមជើងព្រៃបានតាំងឱ្យធ្វើជាមេទ័ព។មេទ័ពជ្វារូបនេះបានគាំទ្រ និងការពារបុត្រមួយអង្គរបស់ព្រះរាមជើងព្រៃ ប៉ុន្តែ នៅពេលដែលពួកនាម៉ឺនសព្វមុខមន្ត្រីបានទទួលស្គាល់ ចៅពញាតន់ ជាក្សត្រមានសិទ្ធិឡើងសោយរាជ្យ គាត់ក៏យល់ស្របតាមគេដែរ ។

ដូច្នេះ ចៅពញាតន់ ក៏បានឡើងសោយរាជ្យសម្បត្តិនៅរាជធានីស្រីសន្ធរ ដោយមានព្រះនាមសម្រាប់រាជ្យថា ព្រះបរមរាជាទី៦ ហើយឯកសារអឺរ៉ុបហៅថា Prauncar។ គួរកត់សម្គាល់ថា គ្រានោះបុត្ររបស់ព្រះរាមជើងព្រៃត្រូវបានពួកជ្វាចិននិងជប៉ុនខ្លះគាំទ្រយ៉ាងសកម្ម ចំណែកឯព្រះបរមរាជាទី៦ មានតែ

ព័រទុយក័ល អេស្ប៉ាញ និងជប៉ុនភាគច្រើនគាំទ្រ ប៉ុណ្ណោះ ។

តាមឯកសារអឺរ៉ុបថា មេទ័ពផ្កាដែលមានងារជា លក្ស៊ីណា (ឯកសារខ្មែរថាជាឈ្មោះទៅវិញ ) មានការច្រណែននិន្ទានឹងជនជាតិអឺរ៉ុប ហើយពុំបានបំពេញកិច្ចការរដ្ឋឱ្យបានដិតដល់ទេ ។ ចំណែកឯពួកទាហានលាវដែលបានដង្ហែចៅពញាតន់ត្រឡប់ចូលស្រុកវិញនោះបានបះបោរ ហើយនៅទីបំផុតក៏ត្រឡប់ទៅវិញអស់ទៅ ។ ដើម្បីជាសគុណ ព្រះបរមរាជាទី៦ បានតែងតាំងលោក វេឡូសូរ ជាចៅហ្វាយស្រុកខេត្តបាណាម ឯលោក រី ជាចៅហ្វាយស្រុកខេត្តទ្រាំង ក៏ដូចជាព្រះបិតារបស់ព្រះអង្គដែរ ព្រះបរមរាជាទី៦ ទ្រង់បានផ្ញើសារទៅក្រុងម៉ានីល ដើម្បីសុំឱ្យពួកបព្វជិតនិមន្តមកប្រទេសខ្មែរដោយទ្រង់សន្យាថានឹងជួយសង់ព្រះវិហារ និងទ្រង់អនុញ្ញាតឱ្យជនជាតិខ្មែរចូលសាសនាគ្រិស្តទៅតាមជំនឿរបស់ខ្លួន ។

បន្ទាប់ពីនោះគេឃើញមានបព្វជិតខ្លះបានមកដល់ប្រទេសខ្មែរដោយចេតនា ខ្លះដោយចៃដន្យ។ ប៉ុន្តែស្ថានភាពរបស់ជនជាតិអឺរ៉ុបពុំបាននឹងនទេ។គេថា ព្រះបរមរាជាទី៦ ជាមនុស្សខិលខូចជាងព្រះបិតាព្រះអង្គទៅទៀត ហើយត្រូវដឹកនាំដោយពួកមហេសី និងព្រះមាតាក្មេកដែលក្លាយជាសហាយរបស់មេទ័ពផ្កាឈ្មោះ លក្ស៊ីណា។ បើតាមលោក រី ថានៅពាក់កណ្ដាលគ.ស.១៥៩៨ទៅហើយព្រះរាជាពុំទាន់បានទទួលរាជាភិសេកសោយរាជ្យសម្បត្តិនៅឡើយ ឯលោក រី និងលោក វេឡូសូរ ក៏ពុំទាន់បានទៅកាន់អំណាចក្នុងខេត្តរបស់ខ្លួនដែរ ។

ដើម្បីពង្រឹងអំណាចរបស់ព្រះអង្គហើយដោយមានសំណើពីលោក រី ផង ព្រះរាជាទ្រង់បានផ្ញើសារទៅជូនលោកទេសាភិបាលថ្មី នៃប្រទេសហ្វីលីពីន ដើម្បីសុំជំនួយជាទ័ពនិងអ្នកផ្សាយសាសនា ។ កាលណោះ មានការជំទាស់យ៉ាងខ្លាំងចំពោះការសុំជំនួយនេះ ប៉ុន្តែលោក ល្វី ប៉េរ៉េ ដាសម៉ារីណាស ទទួលរៀបចំប្រតិបត្តិការមួយ ដោយចេញសោហ៊ុយផ្ទាល់របស់លោក។ នៅថ្ងៃទី១៧ ខែកញ្ញា ១៥៩៨ ក្បូននាវាមួយដឹកនាំទាហានអេស្ប៉ាញ២០០នាក់ បព្វជិតដូមីនីកាំង២អង្គ បព្វជិតហ្វ្រង់ស៊ីស្កាំង២អង្គ បានចេញដំណើរពីក្រុងម៉ានីលឆ្ពោះមកប្រទេសខ្មែរក្រោមបញ្ជាការរបស់លោក Luis Perez Dasmarinas ប៉ុន្តែជាអកុសល ក្បូននាវាត្រូវជួបប្រទះនឹងខ្យល់ព្យុះបក់ទៅទីរនៅប្រទេសចិន ជិតក្រុងកង់តុង ។ ជនដែលរស់រានមានជីវិតទាំងប៉ុន្មានបានត្រឡប់ទៅក្រុងម៉ានីលវិញ។កប៉ាល់មួយដែលបានទទួលបេសកកម្មឱ្យស្វែងរកពួកជនរងគ្រោះហើយដែលបានដឹកនាំទាហាននិងបព្វជិតបានមកដល់ចតុមុខនៅឆ្នាំ១៥៩៩។ជម្លោះមួយបានកើតឡើងរវាងពួកនាវិកអេស្ប៉ាញ និងពួកផ្កា ។ លុះដឹងដំណឹងនេះ លោក វេឡូសូរ និងលោក រី បានមកដល់កន្លែងកើតហេតុហើយត្រូវគេសម្លាប់ទាំងពីរនាក់។ព្រះរាជាលើកទ័ពមកដោយផ្ទាល់ព្រះអង្គហើយត្រូវបានផ្ញើគត់នៅលើសមរភូមិដោយពួកចាមផ្កាបះបោរទៀត ។ គួរគប្បីជ្រាបថា ចំពោះការសោយទីវង្គតរបស់ព្រះបាទបរមរាជាទី៦នេះឯកសារខ្មែរបានផ្ដល់ពត៌មានប្លែកពីពត៌មានរបស់ពួកអឺរ៉ុបទៅវិញ ។ យ៉ាងណាមិញ រាជពង្សាវតារខ្មែរខ្លះបាននិយាយថាកាលព្រះអង្គមានព្រះជន្មបាន២១វស្សាស្ដេចព្រះរាជដំណើរលើកទ័ពចេញទៅចាប់ស្រុកត្បូងឃ្មុំនោះមានចាមឈ្មោះ ប៉ោរ៉ាត១ ផ្កាឈ្មោះ លក្ស៊ីណា១ វាយលុកស្ដេចក្ស័យព្រះជន្មទៅ ។

### ៣. ព្រះបរមរាជាទី៧ ចៅពញាអន(១៥៩៩-១៦០០)

ចៅពញាអន ជារាជបុត្ររបស់ព្រះសត្ថា ត្រូវបានពួកនាម៉ឺនសព្វមុខមន្ត្រីយាងឱ្យឡើងសោយរាជ្យនៅស្រីសន្ធរ ដោយមានព្រះនាមហៅថា ព្រះបរមរាជាទី៧ ហើយបន្តនយោបាយរបស់ដូនតា ដោយអំពាវនាវឱ្យពួកអ្នកផ្សាយសាសនាគ្រិស្តចូលប្រទេសព្រះអង្គ និងឱ្យពួកទាហានមកជួយការពារផងដែរ ។

រាជពង្សាវតារខ្មែរបានបញ្ជាក់ថាស្ដេចអង្គនេះជាក្សត្រមិនប្រកបដោយទសពិធរាជធម៌ ។ ថ្ងៃមួយយាងទៅប្រពាតព្រៃ លុះទៅដល់ភូមិតាមាក់ ទ្រង់សព្វព្រះរាជហឫទ័យស្រឡាញ់ស្ត្រីម្នាក់ជាប្រពន្ធរបស់មេស្រុកឈ្មោះ ពញាចី។ ព្រះអង្គទ្រង់បញ្ជាឱ្យចាប់យកដោយបង្ខំ ហើយដោយស្ត្រីនោះប្រកែក

មិនព្រមផិតក្បត់នឹងប្តីរបស់នាង នាងក៏ត្រូវទទួលរងទារុណកម្មរហូតដល់បាត់បង់ជីវិត។ប្តីរបស់នាងមានសេចក្តីក្តៅក្រហាយខ្លាំងចំពោះអំពើរំលោភជិះជាន់បែបនេះ ក៏រត់ទៅចូលខាង កែវព្រះភ្លើង ។ ក្នុងឱកាសបុណ្យចម្រើនព្រះជន្ម ព្រះបរមរាជាទី៧ កែវព្រះភ្លើងបាននាំបក្សពួកបន្លំចូលធ្វើគត់ព្រះអង្គបាននៅរាជវាំងស្រីសន្ធរ នៅគ.ស.១៦០០ ។

៤. សម្តេចព្រះកែវហ្វា ពញាញោម ( ១៦០០ - ១៦០៣ )

ចៅពញាញោម (បើតាមឯកសារអឺរ៉ុបហៅថា Nacque Sumaday Peraorachyoncar ) ជាបុត្រពៅព្រះសត្ថាទី១ ។ រាជពង្សាវតារខ្មែរថា ព្រះអង្គបានឡើងគ្រងរាជសម្បត្តិស្នងព្រះបិតុច្ឆានៅពេលដែលព្រះអង្គមានព្រះជន្មាយុ២១ព្រះវស្សា ។ ព្រះអង្គមានព្រះនាមសម្រាប់រាជ្យថា សម្តេចព្រះកែវហ្វា គង់នៅព្រះរាជវាំងស្រីសន្ធរ។

ឯកសារអឺរ៉ុបនិយាយថា ព្រះអង្គទ្រង់បានប្រយុទ្ធប្រឆាំងនឹងព្រះបិតុច្ឆា ព្រះនាម ស្រីសុរិយោពណ៌ ដើម្បីបានឡើងសោយរាជ្យ ។ ព្រះអង្គទ្រង់បានលើករាជធានីមកតាំងនៅភ្នំពេញវិញ ( គ.ស.១៦០០ ) ។ព្រះអង្គបានបន្តនយោបាយរបស់ក្សត្រសោយរាជ្យមុនៗព្រះអង្គគឺទ្រង់បានទាក់ទងជាមួយអង្គការផ្សាយសាសនានៅ ម៉ាឡាកា ( Malacca )។ នៅដើមគ.ស.១៦០៣ ទេសាភិបាលអេស្ប៉ាញនៅម៉ានីល បានបញ្ជូនទាហាន និងបព្វជិតខ្លះមកប្រទេសខ្មែរ ជាកិច្ចឆ្លើយតបចំពោះសេចក្តីអំពាវនាវរបស់ចៅពញាអនពេលនោះប្រទេសកំពុងតែមានចលាចល ប៉ុន្តែ ព្រះកែវហ្វា ទ្រង់បានទទួលជនបរទេសទាំងនោះយ៉ាងរាក់ទាក់ណាស់។ ព្រះអង្គទ្រង់បានជួយកសាងព្រះវិហារ ទ្រង់បានផ្តល់ស្បៀងជាអង្ករ ផ្តល់នូវសេរីភាពផ្សាយសាសនានិងការផ្លាស់ប្តូរសាសនាទៀត។

ឯកសារអឺរ៉ុប បាននិយាយបន្ថែមទៀតថា នៅគ.ស.១៦០៣ផងដែល ព្រះស្រីសុរិយោពណ៌ ដោយមានជំនួយទ័ពសៀមផងបានលើកមកវាយឈ្នះព្រះកែវហ្វាហើយស្រុកទេសក៏បានសុខសន្តិភាពចាប់តាំងពីពេលនោះមក ។ ស្តេចខ្មៅ ( ព្រះនរេសូរ ) បាននាំពួកអ្នកផ្សាយសាសនាជាឈ្លើយ យកទៅប្រទេសសៀម។ប្រភពដដែលនេះបានបញ្ជាក់ទៀតថា ដោយទ្រង់ទទួលឥទ្ធិពលខ្លាំងពីសៀមព្រះស្រីសុរិយោពណ៌ ទ្រង់មិននិយមរាប់អានសាសនាគ្រិស្តទេ ហើយទ្រង់បានបញ្ចូលទំនៀមទម្លាប់សៀមមកក្នុងប្រទេសខ្មែរថែមទៀតផង។

ចំណែកឯរាជពង្សាវតារខ្មែរបាននិយាយថា ព្រះកែវហ្វា ជាក្សត្រមិនរវល់នឹងកិច្ចការផែនដី ចូលចិត្តបណ្តើរផ្តែ គង់លើសេះដេញសត្វ បៀតបៀនកូនប្រពន្ធអ្នកដទៃ ជាហេតុបណ្តាលឱ្យនាម៉ឺនជិះជាន់រាស្ត្រ កើតចោរលួចចោរប្លន់ ទើប សម្តេចព្រះទេវីក្សត្រី ត្រូវជាសម្តេចព្រះអយ្យកាជំនុំនឹងមន្ត្រី រួចផ្ញើសារទៅក្រុងស្រីអយុធ្យាក្រាបទូលព្រះចៅសៀមបើកសម្តេចព្រះ ស្រីសុរិយោពណ៌ ឱ្យចេញមកក្រុងកម្ពុជាធិបតី។ ព្រះស្រីសុរិយោពណ៌បានធ្វើមាតុភូមិនិវត្តន៍តាមសំណូមពរពីព្រះអយ្យការបស់ព្រះអង្គដើម្បីមកគ្រប់គ្រងអាណាប្រជានុរាស្ត្រជំនួសព្រះកែវហ្វាចៅពញាញោម ដែលជាស្តេចមិនប្រកបដោយទសពិធរាជធម៌។

គួរគប្បីជ្រាបថា ក្រោយការបែកបាក់បន្ទាយលង្វែកស្រុកទេសបានធ្លាក់ចុះទៅក្នុងស្ថានភាពរឹកររយ៉ាងខ្លាំងមកពីអំណាចកណ្តាលក្នុងរជ្ជកាលមុនៗមានភាពទន់ខ្សោយពេក ។ ម្ល៉ោះហើយ ពួកស្តេចត្រាញ់ក៏តាំងខ្លួនជាធំរៀងៗខ្លួន ដូចជា ព្រះរាមបាទី ព្រះរាមទ្រាំង ព្រះរាមត្បូងឃ្មុំ ព្រះរាមបាភ្នំ។ កាលដែលព្រះស្រីសុរិយោពណ៌ យាងមកដល់ប្រទេសភ្លាមព្រះអង្គយាងទៅគង់នៅកោះស្លាកែត ( ទល់មុខនឹងជ្រោយអំពិលសព្វថ្ងៃ )។ ព្រះអង្គទ្រង់បានបញ្ជាឲ្យលើកទ័ពទៅបង្ក្រាបស្រុកតូចស្រុកធំខ្លះក៏ព្រមចុះចូលខ្លះក៏នៅ ។ ចំណែកឯ កែវព្រះភ្លើង ដែលបានបះបោរតាំងពីរាជ្យព្រះកែវហ្វាចៅពញាញោមនោះត្រូវតេជោមាសលើកទ័ពទៅកំចាត់បាន។ពួកស្តេចត្រាញ់ដែលជាថ្លើងទាំងប៉ុន្មានក៏ត្រូវបានបោសសម្អាតដោយថ្វីដៃព្រះរាជបុត្រទាំងពីររបស់ព្រះអង្គដែ៕

កម្រងទស្សនៈប្លែកៗ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## ១- សេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម

កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ ឯកឧត្តម **សួន លាងហៃ** និងឯកឧត្តម **ថេង ស៊ីធឿន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនៅទីស្តីការគណៈរដ្ឋមន្ត្រីដែលដឹកនាំដោយឯកឧត្តម**កែវ សន្តា** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម។

សេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្មមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការរស់នៅជាប្រចាំរបស់ប្រជាពលរដ្ឋគ្រប់ៗរូប ជាពិសេស ទាក់ទងនឹងការចុះបញ្ជីកំណើត មរណភាព និងអាពាហ៍ពិពាហ៍។

សេចក្តីព្រាងច្បាប់នេះត្រូវបានតាក់តែងឡើងដោយក្រុមការងារតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម ដែលមានសមាសភាពមកពីក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ តាមសេចក្តីសម្រេចលេខ០៤៧ សសរ/គជជអ ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ របស់គណៈកម្មាធិការជាតិដឹកនាំតម្រង់ទិសការងារអត្រានុកូលដ្ឋានស្ថិតិអត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម (គ.ជ.ដ.អ) ដើម្បីអនុវត្តនូវផែនការយុទ្ធសាស្ត្រជាតិស្តីពីអត្តសញ្ញាណកម្មឆ្នាំ២០១៧-២០២៣ ផង និងដើម្បីអនុវត្តឱ្យបានសមស្របតាមផែនការយុទ្ធសាស្ត្រនិងគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការពង្រឹងបន្ថែមនូវកិច្ចការពារសិទ្ធិនិងពង្រឹងការផ្តល់សេវាគ្រប់ប្រភេទ ជូនប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយថែមទៀតផង ក្នុងគោលបំណងធ្វើការកែសម្រួលនូវបទប្បញ្ញត្តិគតិយុត្តណា ដែលពុំទាន់មានភាពសមស្របនិងបំពេញបន្ថែមនូវបទប្បញ្ញត្តិថ្មីៗ ព្រមទាំងបញ្ចូលនូវប្រព័ន្ធថ្មី ដែលពុំធ្លាប់មានប្រើប្រាស់ ដូចជា ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន (ប្រព័ន្ធ IPIS) ជាដើម។ សេចក្តីព្រាងច្បាប់នេះ ក៏ប្រមូលផ្តុំនូវរាល់បទប្បញ្ញត្តិទាំងអស់ដែលទាក់ទងទៅនឹងអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្មដែលពីមុនស្ថិតនៅក្នុងបទដ្ឋានគតិយុត្តផ្សេងៗគ្នាឱ្យនៅក្នុងច្បាប់តែមួយធ្វើឱ្យមានភាពងាយស្រួលដល់អ្នកប្រើប្រាស់ផងនិងអ្នកអនុវត្តច្បាប់ផង។ សេចក្តីព្រាងច្បាប់នេះបានបញ្ចូលជាពិសេសនូវបទប្បញ្ញត្តិ ដែលទាក់ទងទៅនឹងសិទ្ធិ និងកាតព្វកិច្ចជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដើម្បីធានានូវភាពរឹងមាំដែលត្រូវបានការពារដោយច្បាប់។

គោលបំណងសំខាន់នៃសេចក្តីព្រាងច្បាប់នេះ គឺធានាឱ្យមានវិធាន និងនីតិវិធីច្បាស់លាស់ទាក់ទងទៅនឹងការចុះបញ្ជីអត្រានុកូលដ្ឋាន ការចុះបញ្ជីអត្តសញ្ញាណបុគ្គលការចុះបញ្ជីស្នាក់នៅដើម្បីពង្រឹងបន្ថែមទៀតនូវកិច្ចការពារសិទ្ធិនិងពង្រឹងលើកកម្ពស់គុណភាពនៃការផ្តល់សេវាគ្រប់ប្រភេទជូនប្រជាពលរដ្ឋឱ្យកាន់តែទូលំទូលាយ ព្រមទាំងធានាឱ្យបុគ្គលគ្រប់រូបមានអត្តសញ្ញាណបណ្តាតាមផ្លូវច្បាប់ និងជាមូលដ្ឋាន សម្រាប់ការរៀបចំ គ្រប់គ្រងស្ថិតិអត្រានុ-កូលដ្ឋាន និងបញ្ជីប្រជាជន ព្រមទាំងរៀបចំផែនការ

សម្រាប់ អភិវឌ្ឍន៍ផងដែរ។

ពាក្យពេចន៍និងខ្លឹមសារព្រមទាំងទស្សនទាន នៃសេចក្ដីព្រាងច្បាប់នេះរៀបចំឡើងដោយមានភាព ស៊ីចង្វាក់ និងឆ្លើយឆ្លងគ្នាជាមួយច្បាប់ផ្សេងៗ ដូចជា ក្រមរដ្ឋប្បវេណី ច្បាប់ស្ដីពីនីតិវិធីបណ្ដឹងទាក់ទងនឹង ឋានៈបុគ្គលច្បាប់ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែល មិនមែនជាបណ្ដឹង ជាដើម។

សេចក្ដីព្រាងច្បាប់ស្ដីពីអត្រានុកូលដ្ឋាន ស្ថិតិ អត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម មាន ១២ ជំពូក និងមាន ១៨២ មាត្រា ហើយមាត្រានីមួយៗ មានចំណងជើងដូចច្បាប់ធំៗមួយចំនួនកន្លងមក និង មានលេខរៀងកថាខណ្ឌដែលសម្រួលដល់ការចងចាំ ងាយស្រួលក្នុងការអនុវត្ត មិនច្រឡំ មិនពិបាករក។

សេចក្ដីព្រាងច្បាប់នេះបានដាក់ឆ្លងកិច្ចប្រជុំ អន្តរក្រសួងនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ នៅ ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព សម្ដេចក្រឡា ហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ និងកិច្ចប្រជុំពិភាក្សាទាក់ទងនឹងសំណើ កែសម្រួលទម្រង់ និងអក្ខរាវិរុទ្ធមួយចំនួន កាលពី ថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ នៅសណ្ឋាគារ ភ្នំពេញ ក្រោមអធិបតីលោកជំទាវ **ចាន់ សុទ្ធាវី** រដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាប្រធានក្រុមការងារ តាក់តែងសេចក្ដីព្រាងច្បាប់ស្ដីពីអត្រានុកូលដ្ឋានស្ថិតិ អត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម និងលើកចុង ក្រោយ គឺកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនៅទីស្ដីការ គណៈរដ្ឋមន្ត្រី នាថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ ដែល ដឹកនាំដោយឯកឧត្ដម **កែន សត្ថា** រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី។

កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយនេះ បានកែ សម្រួលពាក្យពេចន៍ខ្លះដែលកែពុំទាន់កែអស់ តាម ស្មារតី នៃអង្គប្រជុំអន្តរក្រសួង និងពាក្យពេចន៍ ឃ្លា ប្រយោគខ្លះបន្ថែមទៀត ដើម្បីឱ្យមានន័យកាន់តែ ច្បាស់លាស់ និងមានសង្គតិភាពពីមាត្រាមួយទៅ មាត្រាមួយ និងពីជំពូកមួយទៅជំពូកមួយ។

សេចក្ដីព្រាងច្បាប់នេះ គឺជាសមិទ្ធផលថ្មីមួយ បន្ថែមទៀត ដែលមិនត្រឹមតែសម្រាប់ដោះស្រាយ បញ្ហាដែលបានជួបប្រទះក្នុងការអនុវត្តជាក់ស្ដែង កន្លងមកប៉ុណ្ណោះនោះទេ ប៉ុន្តែធានាបាននូវតម្លាភាព ក្នុងការផ្ដល់សេវាមានលក្ខណៈទំនើបកម្មស្របតាម ការរីកចម្រើននៃសង្គម និងព្យាករណ៍ទុកជាមុនរួច ជាស្រេច ទាក់ទងដល់ការបន្តរីកចម្រើនផ្នែកបច្ចេក វិទ្យាឌីជីថលនាថ្ងៃអនាគតផងដែរ។

*ដោយ សួង លាងហៃ (ក.ស.វ. - ក្រុម ១)*

## ២- សេចក្តីព្រាងអនុក្រឹត្យស្តីពី លក្ខណាវិនិច្ឆ័យ នៃមន្ទីរពិសោធន៍យោង និងមន្ទីរពិសោធន៍ផ្លូវការ

-ម្ហូបអាហារ ជាផលិតផលសម្រាប់បរិភោគ ដែលផ្តល់ថាមពលចាំបាច់សម្រាប់ជីវិតដូចជា ថាមពលសម្រាប់ទ្រទ្រង់ប្រក្រតីភាពនៃសរីរាង្គកាយ ការរីកចម្រើនលូតលាស់រូបរាង្គកាយ ការបញ្ចេញពលកម្ម ហាត់លេងកីឡា ការងារពលកម្ម ដោយរូបសាស្ត្រ។ល។ម្ហូបអាហារក្រខ្វក់គ្មានអនាម័យមានសារធាតុថ្នាំពុលផ្តល់គ្រោះថ្នាក់សម្រាប់សុខភាព។ ម្ហូបអាហារមានគុណភាពសុវត្ថិភាពនិងអនាម័យផ្តល់អត្ថប្រយោជន៍ល្អសម្រាប់សុខភាពអ្នកប្រើប្រាស់។

-ដើម្បីធានាការការពារគុណភាព សុវត្ថិភាព និងអនាម័យម្ហូបអាហារសម្រាប់អ្នកប្រើប្រាស់និងការធ្វើពាណិជ្ជកម្មប្រកបដោយភាពស្មោះត្រង់ ម្ហូបអាហារទាំងនោះ ត្រូវតែបានត្រួតពិនិត្យគុណភាពតាមរយៈការធ្វើវិភាគម្ហូបអាហាររបស់មន្ទីរពិសោធន៍ ដោយផ្អែកលើវិធីសាស្ត្របែបវិទ្យាសាស្ត្រ ដើម្បីកំណត់ភាពអនុលោមរបស់ម្ហូបអាហារឱ្យស្របតាមលក្ខខណ្ឌតម្រូវ នៃបទប្បញ្ញត្តិបច្ចេកទេស ដោយកំណត់អត្តសញ្ញាណសារធាតុចម្លងពីមីក្រូជីវសាស្ត្រ ពីសំណល់សារធាតុថ្នាំពុលកសិកម្ម ថ្នាំការពារ ថ្នាំព្យាបាលសត្វបន្ទាប់ពីផលិតផលម្ហូបអាហារត្រូវបានផលិតនិងបានឆ្លងកាត់គ្រប់ដំណាក់កាលនៃខ្សែច្រវាក់លិតកម្ម ការកែច្នៃ និងការរក្សាទុក។

-អនុក្រឹត្យនេះកំណត់អំពីលក្ខណវិនិច្ឆ័យនិងយន្តការនៃការជ្រើសរើសមន្ទីរពិសោធន៍យោង និងមន្ទីរពិសោធន៍ផ្លូវការ ដើម្បីពង្រឹងគុណភាព សមត្ថភាពមន្ទីរពិសោធន៍ឱ្យមានលក្ខណសម្បត្តិសមស្របក្នុងការផ្តល់សេវាវិភាគម្ហូបអាហារ និងការគាំទ្រ ការធ្វើអធិការកិច្ចម្ហូបអាហារ ដោយក្រសួងស្ថាប័នពាក់ព័ន្ធនិងគុណភាព សុវត្ថិភាពម្ហូបអាហារស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានហើយដែលមានវិសាលភាពអនុវត្តចំពោះគ្រប់មន្ទីរវិភាគម្ហូបអាហារដែលត្រូវបានទទួលស្គាល់និងជ្រើសរើសជាមន្ទីរពិសោធន៍យោង និងមន្ទីរពិសោធន៍ផ្លូវការ។

អនុក្រឹត្យនេះបានអង្គុលបង្ហាញអំពីការដឹកនាំសម្របសម្រួលរបស់គណៈកម្មាធិការមន្ទីរពិសោធន៍វិភាគម្ហូបអាហារតាមការកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ សំណើសេចក្តីព្រាងអនុក្រឹត្យបានឆ្លងកិច្ចប្រជុំបច្ចេកទេស នៅទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី៩ ខែឧសភា និងកិច្ចប្រជុំអន្តរក្រសួង ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ និងឆ្លងការពិនិត្យសម្រេចតាមនីតិវិធីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាបន្តទៀត។

ជារួមអនុក្រឹត្យនេះ ជាឧបករណ៍គតិយុត្តសម្រាប់លើកកម្ពស់និងពង្រឹងគុណភាព សមត្ថភាពមន្ទីរពិសោធន៍សម្រាប់វិភាគម្ហូបអាហារដែលកំណត់អំពីគុណភាពសុវត្ថិភាពអនាម័យមានអត្ថប្រយោជន៍សម្រាប់សុខភាពអ្នកប្រើប្រាស់។

*ដោយ ផាត់ លេង (ក.ស.វ. - ក្រុម ២)*

## III- វិភាគស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌កម្ពុជា ប្រចាំត្រីមាសទី១ ឆ្នាំ២០២៣*



ការវិភាគនេះ ត្រូវបានរៀបចំឡើងក្រោយកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ក.ស.វ) ដើម្បីពិភាក្សាលើស្ថានភាពសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលបានប្រព្រឹត្តទៅនាថ្ងៃអង្គារ ៥ រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២៣ ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រី **ឃឹម ឈុលឡា** ប្រធានក.ស.វ ដែលមានសមាសភាពចូលរួម អនុប្រធានប្រចាំការ អនុប្រធាន ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីទទួលបន្ទុកជួយនាយករដ្ឋមន្ត្រីលើការងារក.ស.វ សមាជិក សមាជិកា ទីប្រឹក្សាបច្ចេកទេសនៃក.ស.វ ព្រមទាំងអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធានផ្នែក មន្ត្រីបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាននៃក.ស.វ និងតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធតាមរយៈប្រព័ន្ធហ្ស៊ូម។ ការវិភាគនេះផ្អែកលើទិន្នន័យព័ត៌មាន ដែលទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ពីអង្គប្រជុំទាំងមូល។

### ១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងអត្រាប្តូរប្រាក់

➡ នាត្រីមាសទី១ ឆ្នាំ២០២៣ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,៩% ធៀបនឹងត្រីមាសមុន និងកើនឡើង១,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង១.១- បម្រែបម្រួលថ្លៃធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន សម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ | | មុខទំនិញ | |
|---|---|---|---|
| ម្ហូបអាហារ | +៣,១% | សាច់គោ | +៤,៩% |
| សម្លៀកបំពាក់និងស្បែកជើង | +២,៨% | បន្លែ | +៤,១% |
| ការកម្សាន្តនិងវប្បធម៌ | +២,៨% | ផ្លែឈើ | +៣,៩% |
| ភោជនីយដ្ឋាន | +២,៤% | ត្រីស្រស់ | +៣,៧% |
| ទំនិញនិងសេវាកម្មផ្សេងៗ | +១,៥% | សាច់មាន់ | +២,៨% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ | +១,៥% | សាច់ជ្រូក | +២,៤% |
| ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | +១,២% | អង្ករ | +២,១% |

* ការវិភាគជាសំណោរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។
ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១- សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងបម្រែបម្រួលជាភាគរយ







តារាង១.២- អត្រាប្តូរប្រាក់

| បរិយាយ | ត្រីមាសទី១ ២០២៣ | ត្រីមាសទី៤ ២០២២ | ត្រីមាសទី១ ២០២២ |
|---|---|---|---|
| ៛/ដុល្លារ | ៤ ០៥៤៛/$ | ៤ ១១៧៛/$ | ៤ ០៥០៛/$ |
| ៛/បាត | ១១៨៛/បាត | ១១៩៛/បាត | ១២២៛/បាត |
| ៛/ដុង | ០,១៧៣៛/ដុង | ០,១៧៤៛/ដុង | ០,១៧៧៛/ដុង |
| បាត/ដុល្លារ | ៣៤,២បាត/$ | ៣៤,៥បាត/$ | ៣៣,៣បាត/$ |
| ដុង/ដុល្លារ | ២៣៤៧៤ដុង/$ | ២៣ ៥៧០ដុង/$ | ២២៨៥៣ដុង/$ |
| យ៉ន់/ដុល្លារ | ៦,៩យ៉ន់/$ | ៦,៩យ៉ន់/$ | ៦,៣យ៉ន់/$ |

## ២. ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

ក្រាហ្វ ២.១- ចំណូលថវិកាជាតិ ឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣ (ប៊ីលានរៀល)




**២.១- ចំណូលថវិកាជាតិ** : អនុវត្តបាន៦ ៧៧០,៦ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ៦៩២,៧ លានដុល្លារ (*មធ្យមប្រចាំខែ៩៦,៨%នៃផែនការ*) ក្នុងនោះចំណូលចរន្តចំនួន៦ ៦៤៨,៣ប៊ីលានរៀល គិតជាដុល្លារអាម៉េរិក ស្មើ១ ៦៦២,១លានដុល្លារ (*មធ្យមប្រចាំខែ១០៤,០% នៃផែនការ*) និងចំណូលមូលធនចំនួន១២២,៣ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ៣០,៦លានដុល្លារ (*មធ្យមប្រចាំខែ១៩,០% នៃផែនការ*) (តាមតួលេខរតនាគារជាតិ)។

➢បើធៀបនឹងត្រីមាសមុន ចំណូលថវិកាជាតិកើនឡើង៥,៥% និងកើនឡើង៦,៧%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំ២០២២។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន៦ ៧១១,៥ប៊ីលានរៀលកើនឡើង១៤,៧%ធៀបនឹងត្រីមាសមុន និងកើនឡើង២០,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន(តាមតួលេខអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ)។ ចំណែកតាមតួលេខរតនាគារជាតិ ចំណូលសារពើពន្ធមានចំនួន៦ ១៥៧,៥ប៊ីលានរៀល កើនឡើង១៣,៣%ធៀបនឹងត្រីមាសមុន និងកើនឡើង២៣,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

✓ចំណូលមិនមែនសារពើពន្ធ មានចំនួន៤៩០,៨ប៊ីលានរៀលថយចុះ៣៩,៥% ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង៦,១%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនa(តាមតួលេខរតនាគារជាតិ)។

**តារាង២.១- មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខរតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -១៦,៦% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (-៤,៦%) | ➢អាជ្ញាបណ្ណក្នុងស្រុក : -៨,៣% | (កើនគំហុក) |
| ➢ ចំណូលពន្ធដារ: +៤៤,៧% (អគ្គនាយកដ្ឋានពន្ធដារ) | (+៩១,០%) | ➢កម្រៃការគ្រប់គ្រងនិងទិដ្ឋាការនាំចេញ:-៨៥,៨% | (-១៦,៥%) |
| | | ➢សម្បទានរ៉ែ: -២៥,៩% | (+១៣,៨%) |
| | | ➢អាកាសចរណ៍ស៊ីវិល: -២៤,៧% | (+១៥១,៣%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: +៥០,៣% | (កើនគំហុក) |

**២.២- ចំណាយថវិកាជាតិ** : អនុវត្តបាន៥ ៦០២,៥ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ៤០០,៦លានដុល្លារ( *មធ្យមប្រចាំខែ៧៤%នៃផែនការ*) ក្នុងនោះ ចំណាយចរន្តចំនួន៤ ២៨១,៨ប៊ីលានរៀល គិតជាដុល្លារអាម៉េរិកស្មើ១ ០៧០,៤លានដុល្លារ( *មធ្យមប្រចាំខែ៨២%នៃផែនការ*) និងចំណាយមូលធនមានចំនួន១ ៣២០,៧ប៊ីលានរៀល គិតជាដុល្លារអាម៉េរិក ស្មើ៣៣០,២ លានដុល្លារ( តាមតួលេខរតនាគារជាតិ )។

ក្រាហ្វ២.២- ចំណាយថវិកាជាតិ ឆ្នាំ២០២០ ដល់ ឆ្នាំ២០២៣ ( ប៊ីលានរៀល )




➢ចំណាយថវិកាជាតិថយចុះ២,១% ធៀបនឹងត្រីមាសមុន និងថយចុះ៤,៩% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តថយចុះ៤,៨% ធៀបនឹងត្រីមាសមុន និងថយចុះ០,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

**២.៣- សមតុល្យថវិកាជាតិ** : ថវិកាជាតិនាត្រីមាសទី១នេះ មានអតិរេកចំនួន១ ១៦៨,១ប៊ីលានរៀល គិតជាដុល្លារ អាម៉េរិកស្មើ២៩២,០លានដុល្លារ ( តួលេខរតនាគារជាតិ )។

## ៣. ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងត្រីមាសទី១ ឆ្នាំ២០២៣មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ □2 មានចំនួន១៧៥ ៧៧២,៨ ប៊ីលានរៀលមានការកើនឡើង២,២%ធៀបនឹងត្រីមាសមុន និងកើនឡើង៧,៧%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ **ការកើនឡើង** □2 ក្នុងត្រីមាសនេះ ជារួមបណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើផ្សេងទៀត១២,៦%។

ក្រាហ្វ៣.១- សមាសធាតុរូបិយវត្ថុ

ត្រីមាសទី១ ឆ្នាំ២០២៣ | ត្រីមាសទី១ ឆ្នាំ២០២២



➢ក្នុងត្រីមាសនេះ ប្រាក់រៀលនៅក្នុង និងក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើរមានចំនួន១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,៤% នៃរូបិយវត្ថុ□2។

តារាង៣.១- សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ □2 ឆ្នាំ២០២២

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅស្ថាប័នទទួលប្រាក់បញ្ញើ | ១៦,៩% | ១៧,0% | ១៦,៦% | | | | | | | | | |
| រូបិយបណ្ណបរទេសនៅក្នុងធនាគារ | ៨៣,១% | ៨៣,0% | ៨៣,៤% | | | | | | | | | |

ក្រាហ្វ៣.២-បម្រែបម្រួលរូបិយវត្ថុក្នុងត្រីមាសទី១ ឆ្នាំ២០២៣

(ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន




តារាង៣.៣-ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំត្រីមាស

| ***បរិយាយ*** | ***ត្រីមាសទី១ ២០២៣*** | ***ត្រីមាសទី៤ ២០២២*** | ***ត្រីមាសទី១ ២០២២*** |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល)<br>ក្នុងនោះ ជារៀល | ១៩៤ ៣៨៩,១<br>២១ ១៨៧,៣ | ១៩៤ ២៤២,៦<br>២០ ៩៧៤,៨ | ១៧១ ៥៣៣,៤<br>១៩ ២៣៨,៣ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (ប៊ីលានរៀល) | ៣៩ ៦៨៣,៦ | ៣៨ ៩៣២,៥ | ៣៣ ៨៥១,៥ |
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៧,៤% | ៦,១% | ៥,៧% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៥,៥% | ៥,៦% | ៣,៨% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១២,២% | ១0,៣% | ១១,២% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៩,១% | ៨,៧% | ៨,៤% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៨,0% | ១៨,0% | ១៧,៣% |
| កម្ចីជារៀលនៅអម្រឹត | ១៧,៩% | ១៧,៦% | ១៦,២% |
| កម្ចីជារៀលនៅប្រាសាក់ | ១៦,៦% | ១២,៥% | ១៦,២% |

## ៤. ស្ថានភាព កសិកម្ម ឧស្សាហកម្ម ថាមពល សេវាកម្ម និងទេសចរណ៍

➡ក្នុងត្រីមាសទី១ ឆ្នាំ២០២៣ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម

➢**កសិកម្ម**:

✓នេសាទសម្រេចបាន២០១,៧ពាន់តោន ថយចុះ៣៤,៥%ធៀបនឹងត្រីមាសមុន ប៉ុន្តែកើនឡើង ២៥,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៣ ៦៩២,៥GWh មានការកើនឡើង២,៣%ធៀបនឹងត្រីមាសមុន និងកើនឡើង៣,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

- អគ្គីសនីផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៩៩៥,៤GWh (ស្មើ២៧,0%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការថយចុះ៥១,៨%ធៀបនឹងត្រីមាសមុន និងថយចុះ៣,៦%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន២ ២២២,៤GWh (ស្មើ៦០,២%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង១០៣,0%ធៀបនឹងត្រីមាសមុន និងកើនឡើង៧៩,៧%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គីសនីផ្គត់ផ្គង់ដោយថាមពលពន្លឺព្រះអាទិត្យ (Solar) មានចំនួន២១១,៤GWh (ស្មើ៥,៧%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង១៤,0%ធៀបនឹងត្រីមាសមុន និងកើនឡើង២២,៩%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- អគ្គិសនីដែលនាំចូលពីប្រទេសជិតខាងដោយ EDC មានចំនួន២៣៥,២GWh (ស្មើ៦,៤%នៃអគ្គិ-សនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា) មានការកើនឡើង១,៩%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ៧៣,0%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។
- និងអគ្គិសនីផ្គត់ផ្គង់ដោយប្រភពផ្សេងទៀតមានចំនួន២៨,២GWh (ស្មើ0,៨%នៃអគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា)មានការថយចុះ២៤,៤%ធៀបនឹងត្រីមាសមុន និងថយចុះ៨៩,៤%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢ផលិតកម្មស៊ីម៉ង់ត៍មានចំនួន២ ១១១,0ពាន់តោនមានការកើនឡើង១៣,៣%ធៀបនឹងត្រីមាសមុន ប៉ុន្តែថយចុះ១៤,0%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

តារាង៤.១- ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូចនិងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –ត្រីមាសទី ១ ២០២៣ | ចំនួន–ត្រីមាសទី ៤ ២០២២ | ចំនួន–ត្រីមាសទី ១ ២០២២ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៤៤ | ៤៤ | ៤៨ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១ ៩៩៧ | ១ ៩៨២ | ១ ៩១៤ |
| ▪ ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បើកថ្មី) | ៣២១ | ២៧៤ | ៣៥១ |
| ▪ឧស្សាហកម្មធុនតូចនិងសិប្បកម្ម (បន្ត) | ៣៥២ | ៣២៨ | ៣៤៤ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន៣ ០៤៥,៧ពាន់ម២ មានការកើនឡើង២៦,៣% ធៀបនឹងត្រីមាសមុន និងកើនឡើង១៥២,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង ១ ២៨៤,៩លានដុល្លារមានការកើនឡើង២៧,៣%ធៀបនឹងត្រីមាសមុន និងកើនឡើង១២៨,៦% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២- សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| បរិយាយ | ពាន់ម២ – ត្រីមាសទី១ ២០២៣ | ពាន់ម២ – ត្រីមាសទី៤ ២០២២ | ពាន់ម២ – ត្រីមាសទី ១ ២០២២ |
|---|---|---|---|
| ▪ លំនៅឋាន | ១ ៤៨១,០ | ១ ៥៧៧,៥ | ២៧៦,៥ |
| ▪ ឧស្សាហកម្ម | ៦៥៥,២ | ២៨១,៨ | ៣៣៦,២ |
| ▪ពាណិជ្ជកម្ម | ៦៧៩,៩ | ៤១៩,២ | ៤៦១,៨ |
| ▪ ទេសចរណ៍ | ៣៣,០ | ១៧,៧ | ៩០,៣ |
| ▪ផ្សេងៗ | ០,០ | ០,០ | ០,០ |
| អនុញ្ញាតសរុប | ៣ ០៤៥,៧ | ២ ៤១១,៤ | ១ ២០៦,១ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាត្រីមាសនេះ គឺលំនៅឋាន៤៨,៦% និងពាណិជ្ជកម្ម២២,៣% នៃផ្ទៃក្រឡាសរុប។

➢**សេវាកម្ម**

តារាង៤.៣-ការចុះបញ្ជីនិងលុបចេញពីបញ្ជីនៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន – ត្រីមាសទី ១ ២០២៣ | ចំនួន – ត្រីមាសទី ៤ ២០២២ | ចំនួន – ត្រីមាសទី១ ២០២២ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ១ ២៦៦ | ៩៧៥ | ១ ៣៦៤ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២១៤ | ២៣៨ | ១៩៧ |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ១ ៧០៧ | ១ ៤២៥ | ១ ៥៩៤ |
| ការស្នើសុំលិខិតអនុញ្ញាត ឬអជ្ញាប័ណ្ណតាមប្រព័ន្ធអេឡិចត្រូនិច | ៥៣ | ៤១ | ១៨ |
| ក្នុងនោះ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ៣៥ | ២៧ | ២ |

➢**ការងារ**

តារាង៤.៤- ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់–ត្រីមាស ទី១ ២០២៣ | នាក់–ត្រីមាស ទី៤ ២០២២ | នាក់–ត្រីមាស ទី១-២០២២ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ( ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ២ ៦១៦ | ១៤ ៥៣៩ | ៤៩៣ |
| អ្នកទទួលបានការងារធ្វើតាមរយៈ ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈនិងទីភ្នាក់ងារជ្រើសរើសឯកជន | ១១២ ២២៦ | ១១៦ ៨៣៣ | ៨៤ ៥៤២ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩៨ ០៩០ | ១០២ ៣១៥ | ៨២ ៧១២ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៤ ១៣៦ | ១៤ ៥១៨ | ១ ៨៣០ |

## ➢ វិនិយោគ

តារាង៤.៥-គម្រោងវិនិយោគអនុញ្ញាតដោយក.អ.ក.(ថ្មីនិងពង្រីក)

| ប្រភេទ | ត្រីមាសទី១ ២០២៣ | ត្រីមាសទី៤ ២០២២ | ត្រីមាសទី១ ២០២២ |
|---|---|---|---|
| អនុញ្ញាតសរុប(លានដុល្លារ) | ២៩៤,០ | ៥៧៣,៣ | ២ ៥២០,៦ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ០,០ | ៤៧,៤ | ៦៦,១ |
| វិស័យឧស្សាហកម្ម (ក្នុងរង្វង់ក្រចកជាតួលេខរបស់តំបន់សេដ្ឋកិច្ចពិសេស) | ២៦២,៧ (៤៦,០) | ១៦៦,០ (៣៣,២) | ៦១១,១ (៣០១,២) |
| វិស័យទេសចរណ៍ | ៣១,៣ | ៣៣២,៤ | ១២៩,០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០,០ | ២៧,៥ | ១ ៧១៤,៤ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៣៩ | ៣៦ | ៤៧ |
| បង្កើតការងារ (ពាន់នាក់) | ៤៦,៨ | ៣១,១ | ៣៨,៧ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ) មានចំនួន៣ ២៥១,៧ ពាន់តោន មានការកើនឡើង២៧,០% ធៀបនឹងត្រីមាស មុន ប៉ុន្តែថយចុះ៧,៤% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។ក្នុងនោះ៖

តារាង៤.៦-ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ(ក្នុងរង្វង់ក្រចកៈ បម្រែបម្រួលធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន)

| | |
|---|---|
| កំពង់ផែភ្នំពេញ: -៣,១% | (-៨,០%) |
| កំពង់ផែកំពង់សោម: +៤៥,៥% | (-៧,២%) |

## ➢ការចុះបញ្ជីនិងចរាចរណ៍

តារាង៤.៧-ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| ប្រភេទ | ចំនួន –ត្រីមាសទី ១ ២០២៣ | ចំនួន–ត្រីមាស ទី៤ ២០២២ | ចំនួន–ត្រីមាស ទី១ ២០២២ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី(ពាន់គ្រឿង) | ៩៦,៩ | ៩១,៦ | ១៤៩,២ |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ២១,៦ | ១៧,២ | ២៦,០ |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ៧៤២ | ៦៩០ | ៨៦៩ |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ៣៧,៧ | -៦៥,៩% | +១៨,២% |
| ក្នុងនោះទទួល | ១០,១ | -៣៦,២% | +១៧,៥% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១០៧,០ | -២៨,៥% | -៤,១% |
| ក្នុងនោះទទួល | ៥៤,១ | +៤៤,០% | -៣៧,៣% |

| ប្រភេទ | ចំនួន | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ១ ៤៧៥,៦ | ១ ៤១៩,០ | ២ ៤៥៧,៥ |
| ក្នុងនោះហៅចូល | ៥៤៨,៥ | ៥២៨,៤ | ១ ០៤១,១ |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១ ៨១២,៨ | ១ ២៧៨,២ | ៣ ៩៥០,០ |
| ក្នុងនោះហៅចូល | ១ ៧៥១,៦ | ១ ៧៥១,៦ | ៣ ៨៨៩,២ |

➢**ការធ្វើដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

តារាង៤.៨-អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍

| ប្រភេទ | ចំនួន(ពាន់នាក់) | %Δ ធៀបនឹងត្រីមាសមុន | %Δធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២៩,២ | +២៥,២% | +៦៥០,០% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ២៣៦,៣ | +៥៤,២% | កើនគំហុក |
| ភ្ញៀវទេសចរចូលទស្សនារមណីយដ្ឋានព្រះវិហារ | ២៤,០ | +១៤,៦% | -១,០% |
| អ្នកដំណើរតាមផ្លូវអាកាស(ក្នុងស្រុក) | ៥៧,៨ | +១៨,០% | កើនគំហុក |
| អ្នកដំណើរតាមផ្លូវអាកាស(អន្តរជាតិ) | ១ ២០២,០ | +៣១,០% | +៥៣៤,៦% |
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស | ១០,៩ | -៩,០% | -៣១,១% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៤០៩,០ | -៤,៨% | កើនគំហុក |
| ចំនួនទេសចរផ្ទៃក្នុង | ៤ ៤៨៧,០ | -២៧,១% | +៤៥,៣% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ១ ២៩១,៥ | +២៧,៨% | +៧១០,៤% |
| ✓ តាមផ្លូវអាកាស | ៤៨១,៦ | +៤៩,២% | +៤៥៣,៧% |
| ✓ តាមផ្លូវគោកនិងផ្លូវទឹក | ៨១០,០ | +១៧,៧% | កើនគំហុក |

## ៥. ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន២២ ៥២៤,៧ប៊ីលានរៀល (ស្មើនឹង៥ ៦៣១,២ លានដុល្លារអាមេរិក) ថយចុះ៥,២%ធៀបនឹងត្រីមាសមុន និងថយចុះ២១,២%ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៥.១-បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|
| ប្រេងសាំង | -១,២% | +២៤,១% |
| ប្រេងម៉ាស៊ូត | +១,៥% | -២៣,២% |
| ឧស្ម័ន | +៧,៦% | +១៣,៧% |
| អគ្គិសនីនាំចូលដោយ EDC | +១,៩% | -៧៣,០% |
| ដែកសំណង់ | +១៩,៨% | +៣៧,២% |
| ស៊ីម៉ងត៍ | -១០,០% | -៤១,៦% |
| ជីកសិកម្ម | -២៦,៥% | -១,២% |
| នាំចូលរបស់ស្ថានទូតមិនធ្វើអាជីវកម្ម | -៣១,០% | -៦០,៦% |
| រថយន្តសរុប (ប៊ី.ល.រ) | -២៦,៦% | -១៦,៦% |
| រថយន្តសរុប (គ្រឿង) | -៣៣,៧% | -២៥,៤% |
| ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -៨,៣% | -៦០,៨% |
| ស្រូវសាលី | -១៤,៥% | -២៨,៦% |
| អង្ករ | +២៤៦,៨% | +៥៧៨,៥% |
| ផ្លែឈើនិងបន្លែ | +៣០,៤% | +១៧០,៩% |
| ថ្នាំកសិកម្ម | -១៤,៥% | -១១,០% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៨,៣% | -០,៧% |

➡ **ការនាំចេញ** ត្រីមាសទី១ ឆ្នាំ២០២៣ មានចំនួន១៨ ៣៥៦,០ប៊ីលានរៀល ស្មើនឹង៤ ៥៨៩,០លានដុល្លារអាម៉េរិក (៨១,៥% នៃការនាំចូល)ថយចុះ៧,៨%ធៀបនឹងត្រីមាសមុន និងថយចុះ៩,១% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន។

តារាង៥.២-បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δ ធៀបនឹងត្រីមាសមុន | %Δ ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន |
|---|---|---|
| ផលិតផលឈើកែច្នៃ | +២៣៤,៧% | -៥៩,១% |
| វាយនភណ្ឌនិងស្បែកជើង | -១១,៧% | -២២,១% |
| អង្ករ | +២,៦% | +៧,៥% |
| ផលិតផលនេសាទ | -២,២% | -៩,៥% |
| កៅស៊ូ | -២៧,៦% | +១៣,៩% |

## ១- គំនិតនៃសង្គ្រាមត្រជាក់

រដ្ឋមន្ត្រីការពារជាតិរបស់ទីក្រុងប៉េកាំង លោក Li Shangfu បាននិយាយថា ជម្លោះយោធារវាងចិន និងសហរដ្ឋអាមេរិក នឹងមានផលវិបាកដ៏អាក្រក់មិនត្រឹមតែសម្រាប់ប្រទេសទាំងពីរប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ពិភពលោកទាំងមូល។“ចិននិងអាមេរិកមានប្រព័ន្ធផ្សេងគ្នា និងខុសគ្នាតាមវិធីជាច្រើនទៀត ទោះជាយ៉ាងណាក៏ដោយ នេះមិនគួររារាំងភាគីទាំងពីរ ពីការស្វែងរកមូលដ្ឋានរួម និងផលប្រយោជន៍រួម ដើម្បីបង្កើនទំនាក់ទំនងទ្វេភាគី និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅនោះទេ”។

រដ្ឋមន្ត្រីការពារជាតិចិន ក៏បានព្រមានថា “ចិត្តគំនិតនៃសង្គ្រាមត្រជាក់ឥឡូវនេះ បានកើតមានឡើងវិញដែលបង្កើនហានិភ័យសន្តិសុខយ៉ាងខ្លាំង”។ លោកមិនបាននិយាយអំពីទីក្រុងវ៉ាស៊ីនតោន និងសម្ព័ន្ធមិត្តដោយផ្ទាល់ទេ ប៉ុន្តែបាននិយាយថា "ប្រទេសមួយចំនួន"បាននឹងកំពុងបង្កើនការប្រណាំងអាវុធ និងជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសផ្សេងទៀត។

យោងតាមរដ្ឋមន្ត្រី Li ការបង្កើតប្លុកយោធា “NATO-like”នៅតំបន់ឥណ្ឌូប៉ាស៊ីហ្វិកបាននឹងកំពុង “ចាប់ប្រទេសក្នុងតំបន់ធ្វើជាចំណាប់ខ្មាំង និងលេងជម្លោះនឹងការប្រឈមមុខដាក់គ្នា”។ជាក់ស្តែងលោកសំដៅទៅលើកតិកាសញ្ញា AUKUS ដែលបានព្រមព្រៀងគ្នារវាងសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស និងអូស្ត្រាលីក្នុងឆ្នាំ២០២១។

ដោយ នរ៉ាណាឫទ្ធិ អានន្ទដាយ៉ាត

## ២- រូបិយប័ណ្ណ BRICS

រូបិយប័ណ្ណ BRICS អាច “ប្រជែងនឹងការគ្រប់គ្រង” នៃស្ថាប័នហិរញ្ញវត្ថុ ដែលដឹកនាំដោយលោកខាងលិច។

ខណៈពេលដែលសហរដ្ឋអាមេរិក ទទួចប្រើស្ថានភាពលេចធ្លោរបស់ប្រាក់ដុល្លារនៅក្នុងប្រព័ន្ធរូបិយវត្ថុពិភពលោកដើម្បីដាក់ទណ្ឌកម្មចំពោះប្រទេសដែលទីក្រុងវ៉ាស៊ីនតោន មិនចូលចិត្តតាមរយៈការដាក់ទណ្ឌកម្ម សេដ្ឋកិច្ច ប្រទេសមួយចំនួននឹងបង្កើតរូបិយប័ណ្ណថ្មីមួយដែលអាចប្រកួតនឹងស្ថានភាពប្រាក់ដុល្លារ — “ ប្រទេសជាច្រើនមានការខកចិត្តចំពោះការគ្រប់គ្រងប្រាក់ដុល្លារ ហើយចង់មានរូបិយប័ណ្ណថ្មីមកជំនួសប្រាក់ដុល្លារ — ដូច្នេះវាហាក់ដូចជាថាការទទួលយករូបិយប័ណ្ណ BRICS នឹងមិនមានបញ្ហាទេ” ។

លោក Mohammed Saqib អគ្គលេខាធិការនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងវប្បធម៌ឥណ្ឌា-ចិន បានប្រាប់ Sputnik លោកបានទទួលស្គាល់ថា ការណែនាំរូបិយប័ណ្ណ BRICS “នឹងតម្រូវឱ្យមានការពុះពារលើបញ្ហាប្រឈមសំខាន់ៗនៃការកសាងទំនុកចិត្តនិងការទទួលយកតាមពេលវេលា”។

លោក Mohammed Saqib ជឿថា "រូបិយប័ណ្ណ BRICS នឹងផ្តល់នូវឋានៈខ្ពស់សម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកចម្រើន ធ្វើការគ្រប់គ្រងកាន់តែខ្លាំងលើកិច្ចការសេដ្ឋកិច្ចពិភពលោក ពង្រឹងអំណាចចរចារបស់ពួកគេក្នុងការចរចាពាណិជ្ជកម្មអន្តរជាតិ និងប្រឈមនឹងការត្រួតត្រានៃស្ថាប័នហិរញ្ញវត្ថុដែលដឹកនាំដោយលោកខាងលិច”។

ដោយ នរ៉ាណាឫទ្ធិ អានន្ទដាយ៉ាត

# ៣- ស្ត្រីខ្មែរ កំពុងបោះជំហានចូលទីផ្សារឌីជីថលយ៉ាងរស់រវើក

បច្ចុប្បន្នប្រជាជនកម្ពុជាទូទាំងប្រទេស រស់ក្រោមពន្លឺសន្តិភាព យ៉ាងសុខក្សេមក្សាន្ត នឹងស្របតាមស្ថានភាពពិភពលោកកំពុងរីកចម្រើនបច្ចេកវិជ្ជាឌីជីថលយ៉ាងខ្លាំងក្លាបានធ្វើឲ្យវិស័យបច្ចេកវិជ្ជាកំពុងផ្លាស់ប្តូរពីទីផ្សារប្រពៃណីមកជាទីផ្សារឌីជីថលយ៉ាងទូលំទូលាយ នឹងនាំមកនូវវឌ្ឍនភាពសេដ្ឋកិច្ចជាតិ។

នេះសឱ្យឃើញថា ទីផ្សារបច្ចេកវិជ្ជាឌីជីថល កំពុងរំដោះស្ត្រីខ្មែរ ឱ្យចេញពីការងារក្នុងផ្ទះ មកប្រកួតប្រជែងទីផ្សារសង្គម និងបានរីករាលដាលពាសពេញពិភពលោក គ្រប់ទីកន្លែងនៅលើផ្លូវឆ្ពោះទៅរកភាពរុងរឿង។ បើពោលឱ្យខ្លី ទីផ្សារបច្ចេកវិជ្ជាឌីជីថល បានផ្តល់មកនូវអត្ថប្រយោជន៍បីសំខាន់ៗដល់ស្ត្រី គឺ៖

ទី១-សន្សំសំចៃពេលវេលា ទីផ្សារបច្ចេកវិជ្ជាឌីជីថលបានផ្តល់អត្ថប្រយោជន៍ដល់ស្ត្រីមានឱកាសធ្វើកិច្ចការផ្ទះផងមើលថែទាំកូនចៅផងនិងប្រកបរបរអាជីវកម្មទីផ្សារតាមអនឡាញផង ដើម្បីពង្រីកជីវភាពគ្រួសារយ៉ាងប្រសើរ។

ទី២-ទីផ្សារបច្ចេកវិជ្ជាឌីជីថលបានផ្តល់ឱ្យស្ត្រីនូវឯករាជ្យភាពសេដ្ឋកិច្ច និងថាមពលរបស់ខ្លួន មិនពឹងពាក់លើបុរសទាំងស្រុង។

ទី៣-ទីផ្សារបច្ចេកវិជ្ជាឌីជីថល ធ្វើឱ្យមានសមភាពយេនឌ័រ ក្នុងការលើកកម្ពស់ស្ត្រី និងកាត់បន្ថយទម្រង់ផ្សេងទៀតនៃការរើសអើងមកលើស្ត្រីកាន់តែប្រសើរឡើង។

ហេតុនេះចំពោះទីផ្សារបច្ចេកវិជ្ជាឌីជីថលបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកម្ពស់ស្ត្រីខ្មែរក៏ដូចស្ត្រីលើពិភពលោក ហើយធ្វើឱ្យស្ត្រីមានពេលវេលាកាន់តែច្រើនដើម្បីបន្ថមហិច្ឆតារបស់ខ្លួន ក្នុងការធ្វើសកម្មភាពកាន់តែប្រសើរដែលធ្វើឱ្យជីវិតស្ត្រីកាន់តែរីករាយ ។

ស្ថិតក្នុងបរិការនេះ ទីផ្សារបច្ចេកវិជ្ជាឌីជីថល បានអនុញ្ញាតឲ្យស្ត្រី ចូលរួមប្រកួតប្រជែងដើម្បីពន្លឿនកំណើនសេដ្ឋកិច្ចគ្រួសារនិងសង្គម។ ព្រោះបុរស ជារឿយៗតែងរាំងដល់ការចូលរួមរបស់ស្ត្រីឲ្យមានព្រំដែនកំណត់។

ស្ថិតក្នុងបរិការនេះ ទីផ្សារបច្ចេកវិជ្ជាឌីជីថល បានអនុញ្ញាតឱ្យស្ត្រីចូលរួមប្រកួតប្រជែងដើម្បីពន្លឿនកំណើនសេដ្ឋកិច្ចគ្រួសារនិងសង្គម។ ព្រោះបុរស ជារឿយៗតែងរាំងដល់ការចូលរួមរបស់ស្ត្រីឱ្យមានព្រំដែនកំណត់។

ដូច្នេះទីផ្សារបច្ចេកវិជ្ជាឌីជីថល បានធ្វើឱ្យស្ត្រីកាន់តែច្រើនឡើងៗមានសេរីភាពក្នុងការសម្រេចចិត្តដោយខ្លួនឯងទាក់ទងនឹងគ្រួសារអាជីពនិងជះឥទ្ធិពលជាវិជ្ជមានដល់ជីវិតរបស់ស្ត្រី។ ការផ្លាស់ប្តូរជាវិជ្ជមាននេះ កំពុងផ្តល់ចំណេះដឹងវិទ្យាសាស្ត្រ ថ្មីៗ ក្នុងការនាំមកនូវវិបុលភាពជីវិតរបស់ស្ត្រីកាន់តែប្រសើរឡើងយ៉ាងស្រស់បំព្រង ៕

ដោយ រ័ត្ន សណ្តាប់

# ការសិក្សាស្រាវជ្រាវសាគរសាស្ត្រ និងធនធានជលផល នៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣-១៩៨៦ (ត)

ដង់ស៊ីតេមធ្យមនៃជីវម៉ាស់ (biomass) ក្នុងតំបន់សេដ្ឋកិច្ចផ្ដាច់មុខ បានប្រែប្រួលពី ១.៨ ទៅ ៥.៥តោន/ម២តាមការអូសអួនពិសោធន៍ស្រាវជ្រាវ។ ជីវម៉ាស់ដែលរកឃើញនៅខែកញ្ញាឆ្នាំ១៩៨៥ មាន ៥.៥៥តោន/ម២ហើយថយចុះដល់៤.៩តោន/ម២នៅខែមេសាឆ្នាំ១៩៨៦ គឺជាដង់ស៊ីតេជីវម៉ាស់ខ្ពស់បំផុតដែលកត់ត្រាបាន។នៅភាគដ៏ធំនៃតំបន់គឺចាប់ពីជំរៅទឹក៣០មែត្រឡើងទៅដង់ស៊ីតេជីវម៉ាស់បានថយចុះតិចជាង ២តោន/ម២ ដែលទោះជាមានការប្រមូលផ្ដុំហ្វូងត្រីច្រើននៅតំបន់នេះក៏ដោយ ក៏វាមិនទៀងទាត់ ហើយក៏រយៈខ្លីដែរ។

ទីខ្ពស់ក្រោមទឹក (shoal) ជិតខាងច្រាំងជាកន្លែងដែលមានផលិតកម្មជីវម៉ាស់ខ្ពស់ ហើយការប្រមូលផ្ដុំហ្វូងត្រី មានភាពនឹងនរនៅស្ទើរទូទាំងឆ្នាំ។ ដង់ស៊ីតេជីវម៉ាស់នៅតំបន់នេះ ប្រែប្រួលពី ២០ ទៅ ៣៣តោន/ម២។ផ្ទៃក្រឡានៃការប្រមូលផ្ដុំនេះប្រែប្រួលពី ៨០០ ទៅ១,២០០ម២ ឯស្ដុកសេដ្ឋកិច្ចប្រែប្រួលពី ១៥,៥០០ ទៅ ២២,០០០តោន (ស្ដុកមធ្យមៈ ≤ ២០,០០០)។សម្រាប់ទីខ្ពស់ក្រោមទឹកជិតខាងច្រាំង ផលនេសាទត្រូវបានផ្ដល់អនុសាសន៍ថាគួរអនុញ្ញាតឲ្យប្រមូលផលពី ៨,០០០ ទៅ ១០,០០០តោន/ឆ្នាំ ដើម្បីធានាចីរភាព។

### ៥.៣.៣ ការងារ ថានានិច្ច័យសាស្ត្រត្រី (fish taxonomy) និងមច្ឆាសាស្ត្រត្រី (ichthyology)

ត្រីដែលនេសាទបានមួយលើកៗ សុទ្ធតែត្រូវបានអ្នកជំនាញថានានិច្ច័យសាស្ត្រ និងជីវសាស្ត្រត្រី តើបយកចេញប្រមាណ១-៣%ពីគំនរត្រីសរុបតាមបរិមាណជាក់ស្ដែងច្រើនឬតិចដើម្បីធ្វើការកំណត់ភិនភាគប្រភេទត្រីទាំងអស់ដែលមានវត្តមាននៅសមុទ្រកម្ពុជា។ បន្ទាប់ពីការកំណត់ភិនភាគរួចមក ត្រីទាំងនោះ ត្រូវឆ្លងកាត់ការងារថ្លឹងទម្ងន់ វាស់វែង និងការវះកាត់ពិនិត្យកំរិតក្រពេញបន្តពូជ សារធាតុខ្លាញ់ក្នុងពោះ និងកំរិតចំណីនៅក្នុងក្រពះ ដោយមានការកត់ត្រាយ៉ាងហ្មត់ចត់ ដើម្បីវិភាគដំណាក់កាលបន្តពូជរបស់ពួកវា។

#### ៥.៣.៣.១ ការងារថានានិច្ច័យសាស្ត្រ (taxonomy)

ការងារនេះត្រូវអនុវត្តនៅគ្រប់ពេលប្រមូលផលត្រីពីការអូសអួននេសាទពិសោធន៍ស្រាវជ្រាវដោយថានានិច្ច័យវិទូស្វែងរកប្រភេទត្រីទាំងអស់បង្ហាញខ្លួនក្នុងផលត្រីដែលនេសាទបានមួយលើកៗ។

ត្រីគ្រប់ប្រភេទ ត្រូវបានឆ្លងកាត់ការវិភាគកំណត់ភិនភាគយ៉ាងហ្មត់ចត់ ដើម្បីធានាឲ្យបានថាឈ្មោះវិទ្យាសាស្ត្ររបស់ ត្រីពិតជាបានកំណត់យ៉ាងត្រឹមត្រូវចំពោះសំណាកត្រីនិមួយៗដែលបានប្រមូលជ្រើសរើសនៅទូទាំងការស្រាវជ្រាវ។ សំណាកគំរូប្រភេទត្រីនិមួយៗ ដែលបានវិភាគកំណត់ភិនភាគត្រឹមត្រូវហើយនោះ ត្រូវបានរក្សាទុកមួយប្រភេទៗចំនួន៤-៥ក្បាលចំពោះត្រីទំហំតូច និង២-៣ក្បាលចំពោះត្រីទំហំធំ ដោយដាក់ត្រាំក្នុងទឹកហ្វ័ម៉ាលីន៥% ដើម្បីរក្សាទុកនៅសារមន្ទីរត្រីពិភពលោកនៅវ្ល៉ាឌីវ៉ូស្ដុក សហភាពសូវៀត (សហព័ន្ធរុស្ស៊ី)។

ត្រីត្រូវបានរកឃើញថាមាន៤៣៤ប្រភេទ (species) ចេញពី៩៦អម្បូរ (family) ដូចតារាងខាងក្រោម៖

## តារាង៥. បញ្ជីអម្បូរត្រីដែលនេសាទបាននៅអំឡុងពេលស្រាវជ្រាវវិទ្យាសាស្ត្រ នៅសមុទ្រកម្ពុជាឆ្នាំ១៩៨៣១-៩៨៦

| ឈ្មោះអម្បូរត្រី និងឈ្មោះខ្មែរ | ចំនួនប្រភេទ | ឈ្មោះអម្បូរត្រី និងឈ្មោះខ្មែរ | ចំនួនប្រភេទ | ឈ្មោះអម្បូរត្រី និងឈ្មោះខ្មែរ | ចំនួនប្រភេទ |
|---|---|---|---|---|---|
| (១) *Orectolobidae* ឆ្លាមឆ្កែ, ឆ្លាមខ្លា | ៥ | (២) *Lomnidae* ឆ្លាមព្រុយពីរ | ១ | (៣) *Scyliorhinidae* ឆ្លាមឆ្មា | ១ |
| (៤) *Carcharhinidae* ឆ្លាមស | ៨ | (៥) *Sphyrnidae* ឆ្លាមឯក | ២ | (៦) *Rhinobatidae* ឆ្លាមត្រួច | ១ |
| (៧) *Rhynchobatidae* ឆ្លាមត្រួច | ១ | (៨) *Dasyatidae* បបែលត្រឡោក | ៩ | (៩) *Gymnuridae* បបែលមេអំបៅ | ១ |
| (១០) *Myliobatidae* បបែលអក | ៥ | (១១) *Torpedinidae* បបែលឆក់ | ៣ | (១២) *Megalopidae* ត្រីព្រុយវែង | ១ |
| (១៣) *Clupeidae* ត្រីកាម៉ិយ/គុន | ២០ | (១៤) *Engraulidae* ត្រីធន្លញមាន់ | ៨ | (១៥) *Chirocentridae* ត្រីស្រោមដាវ | ១ |
| (១៦) *Synodontidae* ត្រីថ្លែន, ត្រីត្លូចិន | ៦ | (១៧) *Ariidae* ត្រីគ្អុក | ៦ | (១៨) *Plotosidae* ត្រីអណ្តែងសមុទ្រ | ២ |
| (១៩) *Muraenidae* អន្ទង់ | ៤ | (២០) *Muraenesocidae* អន្ទង់ស | ២ | (២១) *OphiChthidae* អន្ទង់ | ១ |
| (២២) *Belonidae* ត្រីផ្ទោងព្រ៉ែត្រ | ២ | (២៣) *Bregmacerotidae* ត្រីគុជតូច | ១ | (២៤) *Fistulariidae* ត្រីមាត់ខ្លុយ | ២ |
| (២៥) *Centriscidae* ត្រីពួន/បង្កា | ២ | (២៦) *Syngnathidae* ចៃក្រពើ | ៣ | (២៧) *Holocentridae* ត្រីក្រហមស្រកាធំ | ២ |
| (២៨) *Monocentridae* ត្រីម្នាស់ | ១ | (២៩) *Sphyraenidae* ត្រីអង្រែ | ៧ | (៣០) *Mugilidae* ត្រីស្បែក | ៣ |
| (៣១) *Polynemidae* ត្រីកាវ៉ាវ | ៣ | (៣២) *Serranidae* ត្រីតុកកែ | ២៣ | (៣៣) *Theraponidae* ត្រីក្រសក់ | ៥ |
| (៣៤) *Priacanthidae* ត្រីក្រហមភ្នែកធំ | ៣ | (៣៥) *Apogonidae* ត្រីព្រុយស្តើង | ៧ | (៣៦) *Sillaginidae* ត្រីព្រលូស | ២ |
| (៣៧) *Lactariidae* ត្រីស្លឹកខ្នុរ | ១ | (៣៨) *Rachycentridae* ត្រីផ្ទក់ | ១ | (៣៩) *Carangidae* ត្រីកាំតូច/គូនធំ | ៣៨ |
| (៤០) *Formionidae* ត្រីចាបខ្មៅ | ១ | (៤១) *Menidae* ត្រីតាំងតោ/ក្លឹតឃ្មុំ | ១ | (៤២) *Lutjanidae* ត្រីអាំងកើយ | ១៩ |
| (៤៣) *Nemipteridae* ត្រីក្រហម/ឥន្ទនូ | ២០ | (៤៤) *Lobotidae* ត្រីក្រាញ់សមុទ្រ | ១ | (៤៥) *Leiognathidae* ត្រីកិ/សំពោរហៀរ | ១៥ |
| (៤៦) *Gerridae* ត្រីកញ្ជាក់ស្លា/ជួរអង្ករ | ៥ | (៤៧) *Pomadasyidae* ត្រីបង្កង់លឿង | ៧ | (៤៨) *Sciaenidae* ត្រីចង្កូមបី | ១៥ |
| (៤៩) *Lethrinidae* ត្រីមង្សុត/គ្រាប់ខ្នុរ | ៦ | (៥០) *Pentapodidae* ត្រីក្រាញ់ស | ៣ | (៥១) *Mullidae* ត្រីពពែ | ១២ |
| (៥២) *Ephipidae* ត្រីឃុត/ចៀកដំរី | ១ | (៥៣) *Platacidae* ត្រីប្រាជៀវខ្មៅ | ១ | (៥៤) *Drepanidae* ត្រីកណ្ដៀវ | ២ |
| (៥៥) *Scatophagidae* ត្រីខ្លា | ១ | (៥៦) *Chaetodontidae* ត្រីមេអំបៅ | ៩ | (៥៧) *Cepolidae* ត្រីបន្ទះសំប៉ែត | ១ |
| (៥៨) *Pomacentridae* ត្រីត្លុកក្រមុំ | ៤ | (៥៩) *Labridae* ត្រីសេក | ៦ | (៦០) *Scaridae* ត្រីសេកខៀវ | ២ |
| (៦១) *Mugiloididae* ត្រីក្រាញ់ខ្សាច់ | ២ | (៦២) *Uranoscopidae* ត្រីខ្មោច | ១ | (៦៣) *Champsodontidae* ត្រីធ្មេញក្រពើ | ២ |
| (៦៤) *Callionymidae* ត្រីនាគតូច | ១ | (៦៥) *Blennidae* ត្រីធ្មេញញឹក | ២ | (៦៦) *Derepodichthydae* ត្រីខ្ទឹងស | ១ |
| (៦៧) *Brotulidae* ត្រីស្អក់សមុទ្រ | ១ | (៦៨) *Siganidae* ត្រីកន្លាង | ៣ | (៦៩) *Trichiuridae* ត្រីគុក | ២ |
| (៧០) *Scombridae* ត្រីបេកា/កាឡាំង/ឈាម | ៩ | (៧១) *Xiphiidae* ត្រីចំពុះដាវ | ១ | (៧២) *Stromateidae* ត្រីចាបស | ១ |
| (៧៣) *Ariommidae* ត្រីកន្ទុយចំពាម | ១ | (៧៤) *Gobiidae* ត្រីប្រម៉ុង | ៣ | (៧៥) *Gobioididae* ត្រីប្រម៉ុងអន្ទង់ | ៣ |
| (៧៦) *Scorpaenidae* ត្រីខ្យាដំរី | ៧ | (៧៧) *Triglidae* ត្រីព្រុយស្លាប | ១ | (៧៨) *Synanceiadae* ត្រីបីសាច | ២ |
| (៧៩) *Platycephalidae* ត្រីក្បាលសំប៉ែត | ៦ | (៨០) *Duotylopteridae* ត្រីមេអំបៅ | ២ | (៨១) *Psettodidae* ត្រីអណ្តាតឆ្កែ | ១ |
| (៨២) *Bothidae* ត្រីអណ្តាតឆ្កែ | ១១ | (៨៣) *Pleuronectidae* ត្រីអណ្តាតឆ្កែ | ២ | (៨៤) *Soleidae* ត្រីអណ្តាតឆ្កែ | ៤ |
| (៨៥) *Cynoglossidae* ត្រីអណ្តាតឆ្កែ | ៤ | (៨៦) *Echeneidae* ត្រីជញ្ជក់ | ២ | (៨៧) *Triacanthidae* ត្រីធ្មុងបី | ១ |
| (៨៨) *Balistidae* ត្រីកញ្ជ្រូកសមុទ្រ | ៨ | (៨៩) *Monacanthidae* ត្រីអង្រួស | ១ | (៩០) *Psilocephalidae* ត្រីមុស | ១ |
| (៩១) *Ostraciontidae* ត្រីប្រអប់ | ៤ | (៩២) *Tetraodontidae* ត្រីកំពត | ១០ | (៩៣) *Diodontidae* ត្រីកំពតបន្លា | ២ |
| (៩៤) *Batrachoididae* ត្រីគីង្គក់ | ១ | (៩៥) *Antennariidae* ត្រីគីង្គក់ | ២ | (៩៦) *Pegasidae* ត្រីកែសមុទ្រ | ៣ |

### ៥.៣.៣.២ ការងារមច្ឆាសាស្ត្រ (ichthyology)

ត្រីទាំង៤៣៤ប្រភេទចេញពី៩៦អម្បូរដែលរកឃើញនៅអំឡុងពេលស្រាវជ្រាវនៅសមុទ្រកម្ពុជាពីឆ្នាំ១៩៨៣-១៩៨៦ មានត្រីចំនួន ១៧៤ ទៅ ៣១១ ប្រភេទបានបង្ហាញខ្លួនជាញឹកញាប់ក្នុងផលត្រីដែលនេសាទបានស្ទើរតែទាំងអស់ ក្នុងនោះមាន៩០ ទៅ ១២០ប្រភេទ មានលក្ខណៈជាប្រភេទត្រីសេដ្ឋកិច្ច ដោយពួកវាបានបង្ហាញខ្លួនពីចំនួន៨៣%នៃត្រីដែលនេសាទបាននៅចន្លោះខែកក្កដា-សីហា ឆ្នាំ១៩៨៣ ទៅចំនួន៩២% នៅចន្លោះខែកម្ភៈ-មេសា ឆ្នាំ១៩៨៦ ទោះជាយ៉ាងនេះក៏ដោយ ក៏មានត្រីចំនួន ៦ប្រភេទ៖ គឺត្រីកិស្រស់ (Leiognatus splendens), ត្រីប្លាធូ ឬ ត្រីកាម៉ុង (Rastrellizer brachysoma), ពួកត្រីកន្ទុយរឹង (Chinchard) ក្នុងនោះ ៖ (១) ត្រីគួនគុំ (Atulemate), (២) ត្រីផ្ទួតលឿង (Salaroides leptolepis), (៣) ត្រីកន្ទុយរឹង (Megalaspis cordyla)

(៤) ត្រីកន្ទុយរឹងមូល (Decapterusmaruadsi) អាចចាត់ទុកថាជាប្រភេទត្រីសេដ្ឋកិច្ចសំខាន់ជាងគេ។

ត្រីទាំង៦ប្រភេទខាងលើនេះ បានក្តាប់យក ៤៨% នៃត្រីដែលចាប់បាននៅខែកក្កដាឆ្នាំ១៩៨៣ ៣៥.១% នៅខែឧសភា ឆ្នាំ១៩៨៥ ៣០.៩% នៅខែកក្កដា ឆ្នាំ១៩៨៥ ២៣.១% នៅខែកុម្ភៈ ឆ្នាំ១៩៨៦ និង ៣៥.៨% នៅ ខែមេសាឆ្នាំ១៩៨៦។ ការបង្ហាញខ្លួនរបស់ពួកវាបានធ្លាក់ចុះពី ១៩% នៅខែកញ្ញា ឆ្នាំ១៩៨៥ ដល់១២.៥% នៅខែធ្នូ ឆ្នាំ១៩៨៥។ ឯរបាយប្រភេទត្រីសេដ្ឋកិច្ចដែលចាប់បានក្រៅពីនោះ ត្រូវបែងចែកជា២ក្រុម៖ ក្រុមទី១ជាពពួកដែលបង្ហាញខ្លួនញឹកញាប់ តែបរិមាណប្រែប្រួលទៅតាមដំណាក់កាលខុសៗគ្នា ជួនកាលក៏គ្មានសោះតែម្តង ទោះជាផលចាប់បានច្រើនក៏ដោយ និងមានម្តងម្កាល ក៏មានបរិមាណសម្បូរបែបដែលអាចមកពីការប្រមូលផ្តុំហ្វូងធ្វើបន្លាស់ទី។ក្រុមនេះមានប្រហែល១៥-២០ប្រភេទដែលមានជាអាទិ៍៖ ត្រីកាំគួច (Alepes kalla), ត្រីអណ្តែងសមុទ្រ (sea catfish), ត្រីផ្លិតឃ្មុំឬតាំងតោ (Mene), ត្រីកាំគួច/កាឡាងធំៗ (some big Caranx sp.), ត្រីអាំងកឹយ (Lutjanidae), ត្រីត្រសក់ (Therapon theraps), ត្រីកាវ៉ាវ (Eleutheronema), ត្រីគូន (Clupeidae)។ ក្រុមទី២ មាន៧៥ប្រភេទ ក្នុងបរិមាណតិចតួច តែបង្ហាញខ្លួនញឹកញាប់គួរសម ដែលអាចនិយាយបានថាជាប្រភេទដែលមានរបាយពន្ធុ (gene) តែមួយនៅផ្នែកណាមួយនៃតំបន់ដែលស្រាវជ្រាវដែលមិនធ្វើការប្រមូលផ្តុំហ្វូងដូចជាប្រភេទត្រីក្បកក្រហម (Mullidae), ត្រីថ្លែន (Sauridae) ជាដើម។ ប្រភេទផ្សេងទៀត គ្មានលក្ខណៈសេដ្ឋកិច្ចទេព្រោះការបង្ហាញខ្លួនរបស់ពួកវាមិនជាញឹកញាប់ឯបរិមាណក៏មានមិនច្រើនដែរ។

របាយសមាសភាពនិងស្ថានភាពត្រីដែលចាប់

**បានទៅតាមជំរៅទឹកនិងរដូវកាល**

នៅតំបន់ខាងជើងខ្សែរយៈទទឹង ១១°00N ការនេសាទដោយប្រើអួនអូសនៅជំរៅទឹកតិចជាង ៣០ម៉ែត្រ បានទទួលផលមិនលើសពី០.៥-២តោន/ម៉ោងឡើយនៅគ្រប់រដូវទាំងអស់។ ត្រីដែលនេសាទបានមាន៖ ត្រី គូនគុំ (Atule), ត្រីកន្ទុយរឹងពោះស្រួច (Alepes kalla), ត្រីកន្ទុយរឹងមូល (Decapterus russelli), ត្រីកាម៉ៃយ (Clupeidae)។ នៅតំបន់ខាងត្បូងខ្សែរយៈទទឹង១១°00N ក្នុងដែនសមុទ្រកម្ពុជាផលិតភាពត្រីមានកំរិតខ្ពស់នៅទូទាំងឆ្នាំ។ នៅរដូវភ្លៀង បរិមាណទឹកសាបចេញពីទ្វីបហូរចូលទៅតំបន់ឆ្នេរ តាមរយៈឆកកំពង់សោម បង្កើតបានជាកន្លែងដែលមានការប្រមូលផ្តុំហ្វូង នៃប្រភេទត្រីសេដ្ឋកិច្ចពិសេស។ នៅរដូវប្រាំង ភាពសម្បូរត្រីនេះត្រូវបានប្រទះឃើញនៅតំបន់ខាងក្រៅសមុទ្រកម្ពុជាដែលអាចសន្និដ្ឋានបានថាទឹកសាបហូរចេញពីទ្វីបតាមទន្លេធំៗចំនួនបីនៅឯនាយកោះត្រល់បានបន្សាបទឹកនៅមាត់ឈូងសមុទ្រថៃ។

ផលនេសាទដែលសម្បូរត្រូវប្រទះឃើញនៅជិតច្រាំងក្នុងចន្លោះជំរៅទឹក១២-២០ម៉ែត្រ។ ប្រសិទ្ធិភាពនេសាទមិនមែនមានតែនៅក្នុងខែកុម្ភៈ-មេសា ឆ្នាំ១៩៨៦ នៅចន្លោះជំរៅនេះប៉ុណ្ណោះទេ គឺផលត្រីដែលចាប់បានដោយអូសអួនអំឡុងពេលសាវជ្រាវឆ្នាំ១៩៨៣-១៩៨៦ទាំងអស់ នៅក្នុងតំបន់នេះ សុទ្ធតែខ្ពស់ក្នុងបរិមាណពី៥៤០គក្រទៅ៥៣៣គក្រ/ម៉ោងនៃការអូសអួនដោយមានត្រីចំនួន១៥០ប្រភេទនៅក្នុងផលចាប់ផលចាប់ទាំងនោះផង។ នៅខែកុម្ភៈ ក្នុងចំណោមត្រីកិ/សំបោរហៀរ (Leiognathidae) ទាំងប្រាំមួយប្រភេទ ដែលក្តាប់យក១៩.៦%នៃផលចាប់មានពីរប្រភេទដែលមានបរិមាណច្រើនជាងគេគឺ៖ ត្រីកិស្រស់ (Leiognatus splendens) និងត្រីសំបោរហៀរគ្មានរំអិល (Gazza minuta)។ នៅខែមេសាអត្រាពួកត្រីកិ/សំបោរហៀរ បានកើនឡើងដល់៣១% ដែលអាចបញ្ជាក់បានពីការធ្វើបន្លាស់ទីរបស់ពួកវាពីតំបន់ជំរៅទឹក២០-២៧ម៉ែត្រមកផ្ទៃលើទឹក។ពពួកត្រីកាំគួចចំនួន២១ប្រភេទ ក្តាប់យក ១៩% នៅក្នុងផលចាប់និមួយៗដែលក្នុងនោះមានត្រីកន្ទុយរឹងឆ្នូតលឿង

(Sela), ត្រីកន្ទុយរឹងពោះស្រួច (Alepes kalla), ត្រីបេកា (Scombridae) និងប្រភេទត្រីកាំគួចធំៗ ដូចជា ត្រីបេកាអុច (Scomberoides lysan), ត្រីអំបោះ (Alectis indicus), និងត្រីកាំគួចឆ្នូត (Gnathonodonspeciosus)។ក្រោយពិនិត្យលើផលចាប់ដោយការអូសអួនទាំងអស់មក គេ អាចកំណត់តំបន់ប្រមូលផ្តុំហ្វូងត្រីជាសំខាន់ គឺនៅចន្លោះជំរៅទឹក១២-២៧មែត្រ (រូបភាព៤, ៥)។

នៅចន្លោះជំរៅទឹក២០-៣០មែត្រផលនេសាទជាមធ្យម ក្នុងអំឡុងពេលពាក់កណ្តាលខែឧសភាដល់ពាក់កណ្តាលខែកក្កដាឆ្នាំ១៩៨៥ និងអំឡុងខែកុម្ភៈ-មេសាឆ្នាំ១៩៨៦ ប្រែប្រួលចាប់ពី ៣២១គក្រទៅ៤៨៦គក្រ/ម៉ោង នៃការអូសអួនពិសោធន៍ ដោយមានត្រីចំនួន១២៥-១៦០ប្រភេទនៅក្នុងផលត្រីដែលចាប់ទាំងនោះផង។ ត្រីសំខាន់ក្នុងចំណោមត្រីកិ (Leiognathidae) មាន៖ ត្រីកិស្រស់ (Leiognatus splendens), ត្រីសំបោរហៀរ គ្មានរំអិល (Gazza minuta), ត្រីកិព្រុយក្រហម (Leiognatus bindus) ក្នុងចំណោមត្រីកាំគួច (Carrangidae) មាន ត្រីកូនគុំ (Atule mate), ត្រីភ្នែកស (Selar boops), ត្រីកន្ទុយរឹងពោះស្រួច (Alepes kalla), ពពួកត្រីចោរធំៗ៥ប្រភេទ (5 Caranx sp.), ត្រីប៉ាឡាំង (mack erel), ត្រីបេកាអុច (Scomberoides), ត្រីចិនចាស់ (Alectis), ត្រីប្លាធូ/កាម៉ុង (Rastrellizer), ត្រីត្រសក់ (Therapon theraps), ត្រីត្រសក់ឆ្នូតបួន (Pelates quadrilineatus), ត្រីគូន (Sardinella), ត្រីបណ្តូលចេកភ្នែកក្រហម (Etrumus teres), ត្រីកាម៉ុយ (Anodontostomachacunda),ត្រីអាំងកឹយព្រុយខ្មៅ (Lutjanus buccanella), ត្រីស្រកាទន់ក្រហម (Pritipomoides), ត្រីអាំងកឹយខៀវ (Lut janus tachete), ត្រីកាជីឆ្នូត (Plectorhinchus cinctus)និងត្រីផ្សេងទៀត។គេមិនអាចកំណត់ប្រភេទត្រីដែលមានលើសលុបនៅទូទាំងរដូវបានឡើយប៉ុន្តែជំរៅទឹកអាចបង្ហាញលក្ខណៈប្រែប្រួលនៃសមាសភាពត្រីដែលចាប់បាន (រូបភាព៤, ៥)។

នៅចន្លោះជំរៅទឹក១៨-៣៥មែត្រក្នុងខែមិនាត្រីក្អុកអាហ្វ្រិក (Ariusafricanus) បានផ្លាស់ទីទៅរកតំបន់ក្បែរច្រាំងដើម្បីពងកូនព្រោះពួកវាអវត្តមាននៅតំបន់ទឹកជ្រៅ។ នៅចុងខែវិច្ឆិកា ប្រភេទត្រីក្អុកផ្សេងទៀតដូចជាត្រីក្អុកទន្លេ (Arius caelatus) ត្រីក្អុកសសៃ (Arius venosus) អវត្តមានពីសមុទ្រកម្ពុជា ព្រោះ បានធ្វើបន្លាស់ទីទៅរកកន្លែងពងកូននៅទន្លេ ទឹកសាប។ត្រីកន្ទុយរឹង (Megalaspis cordyla) ពងកូនច្រើន បំផុតនៅចុងខែកុម្ភៈ ដែលនៅដើមខែកុម្ភៈ ត្រីករពងមានចំនួន ៦% នៅចុងខែកុម្ភៈមាន ៦០% នៅចុងខែមិនាមាន ៣០% និងនៅចុងខែមេសាមាន១៦%។នៅអំឡុងខែឧសភា-កក្កដា និងកញ្ញា-ធ្នូត្រីកន្ទុយរឹងមិនចិតនៅក្នុងដំណាក់កាលពងកូនឡើយ។ ដំណាក់កាលពងកូនជាអតិបរិមា នៃត្រី កូនគុំ (Atule mate) គឺនៅចុង ខែកុម្ភៈ (៣៦%) នៅដើមខែមេសា (៥១%) ដែលនៅដើមខែមិនា និងដើមខែមេសា បរិមាណត្រីកពងបានធ្លាក់ចុះដល់១២% និង១៥%។ក្នុងចន្លោះពេលខាងលើនេះ បរិមាណត្រីកពងបានកើនឡើងដល់៣០%នៅចុងខែមិនា។ខួបនៃដំណាក់កាលពងកូននេះ កើតឡើងប្រហាក់ប្រហែលគ្នាទៅលើប្រភេទត្រីផ្សេងៗទៀត ដូចជា ត្រីអាំងកឹយភ្នែកធំ (Pristipomoides macrophthal mus) ត្រីឆ្កង់ប្រផេះ (Lutjanus vitta) ត្រីត្រសក់ (Therapon theraps) ត្រីកន្ទុយរឹងភ្នែកធំ (Selar crumenophthalmus) ត្រីចង្កូមខ្លា (Argyrosomus argentatus) ត្រីកាំគួចច្រមុះវែង (Carangoides chrysophrys) ត្រីការ៉ាវ (Eleutheronema)ជាដើម។ ពពួកត្រីខាងក្រោយនេះធ្វើការបន្តពូជជារបៀបប្រមូលផ្តុំហ្វូងតូចៗ រួចហើយបែកខ្ញែកគ្នាទៅគ្រប់កន្លែងក្នុងតំបន់ដើម្បីពងកូន។ ប្រភេទត្រីខ្លះ ដូចជា ត្រីកាជីអុចខ្នង (Pomadasys maculates) ត្រីគូន (Dussum ieria acuta) ត្រីត្រសក់ (Therapon theraps) ត្រីត្រសក់កន្ទុយឆែក (Paletes quadrillineatus) ត្រី-

ត្រីភ្នែកស (Selar boops) ត្រីកាម៉យ (Anodontostoma Chacunda) ត្រីផ្លិតឃ្មុំ (Mene) ជាដើម មានរយៈពេល ពងកូនខ្លីបំផុតដែលតាមលក្ខណៈរបាយរបស់វា គេអាចចាត់ទុកថាជាក្រុមតែមួយ។ ប្រភេទនិមួយៗបានចូលមកក្នុងតំបន់ជាហ្វូងធំព្រោះការពងកូនរបស់ពួកវាកើតឡើងដំណាលគ្នា។ ក្រោយពេលពងកូនដែលមានរយៈពេលខ្លី (២-៤ សាប្តាហ៍) រួចមក ពួកវាបានផ្លាស់ទីទៅតំបន់ទឹកជ្រៅ ដែលដោយហេតុនោះពួកវាមិនបានបង្ហាញខ្លួនទាំងស្រុងឬស្ទើរតែទាំងស្រុងនៅក្នុងផលត្រីដែលចាប់បានដោយការអូសអួនស្រាវជ្រាវ។ នៅអំឡុងខែឧសភា-កក្កដា បរិមាណត្រីមេករពងមានមិនលើសពី១៥-២០%ឡើយ។ អំឡុងខែកក្កដា-សីហា ត្រីករពង មាន១៨% តែត្រីប្លាធូមានត្រីមេករពងរហូតដល់៤១% ឯត្រីកូនគុំមេ៥៨%បានពងកូននៅដើមខែកក្កដា។ នៅអំឡុងខែកញ្ញា-ធ្នូ បរិមាណត្រីមេករពងមានចំនួន១០% នៅតំបន់ក្បែរច្រាំង (រូបភាព៥,៦,៧,៨,៩)។

នៅជំរៅទឹកពី៤០-៥០មែត្រ ផលនេសាទជាមធ្យម នៅក្នុងខែឧសភា ឆ្នាំ១៩៨៥ មានចំនួន ១៧៣គក្រ/ម៉ោងនៃការអូសអួនពិសោធន៍។ផលចាប់ដែលប៉ាន់ស្មាននៅរដូវនានាទូទាំងឆ្នាំមានមិនលើសពី១១៥គក្រ/ម៉ោងនៃការអូសអួនស្រាវជ្រាវឯប្រភេទត្រីដែលច្រើនលើសលប់គឺៈ ត្រីកូនគុំ (Atule) ត្រីកន្ទុយរឹង (Megalaspis cordyla) ត្រីភ្នែកស ត្រីចេក (Seriolina nigrofasciata) ត្រីក្រហមផ្កាថ្ម (Priacanthus arenatus) ត្រីក្បួកក្រហម (Mulii dae) និងត្រីប្លាធូ/កាម៉ុង (Rastrellizer)។ការប្រមូលផ្តុំហ្វូងភាគច្រើននៃត្រីត្រូវបានប្រទះឃើញនៅជំរៅទឹកលើសពី៣០មែត្រឡើងទៅ នៅតំបន់បរិមណ្ឌលនៃចលនាព្យុះស៊ីក្លូន។ ផលត្រីចាប់បានក្នុងកំរិតទាបប្រមាណ ៥០០គក្រ/ម៉ោងនៃការអូសអួនពិសោធន៍ត្រូវបានប្រទះឃើញនៅតំបន់ចំណុចកណ្តាល នៃចលនាគួចរបស់ព្យុះស៊ីក្លូន។លក្ខខណ្ឌនៃការប្រមូលផ្តុំហ្វូងត្រីប្រែប្រួលតាមការវិវត្តន៍នៃឌីណាមិកទឹក។

ចាប់ពីជំរៅទឹកលើសពី៥០មែត្រឡើងទៅផលត្រីនេសាទបានមានកំរិតទាបនៅស្ទើរគ្រប់កន្លែងក្នុងតំបន់សេដ្ឋកិច្ចផ្តាច់មុខកម្ពុជា។ផលត្រីដែលចាប់បានជាអតិបរិមានៅខែកុម្ភៈឆ្នាំ១៩៨៦ អាចកំណត់បានជាមធ្យមថាមានបរិមាណ១២២គក្រ/ម៉ោងនៃការអូសអួនពិសោធន៍។ភាគខាងត្បូងតំបន់នេះបានបង្ហាញពីការប្រមូលផ្តុំហ្វូងត្រីកើនឡើងនៅគ្រប់រដូវ។ មានម្តងម្កាលនៅជំរៅទឹកនេះ ត្រីដែលចាប់បានជាអតិ-បរិមាមានដល់ ៦៦០គក្រ/ម៉ោងនៃការអូសអួនពិសោធន៍ ដែលជាប្រភេទត្រីធំដូចជាៈ ត្រីអាំងកឹយក្រហម (Lutjanus argentimaculatus) ត្រីអាំងកឹយថ្ម (Pinjalopinjalo)។ជាទូទៅប្រភេទត្រីច្រើនលើសលប់ជាងគេដែលសង្កេតឃើញនៅតំបន់ជំរៅទឹកនេះមានៈ ត្រីក្រហមផ្កាថ្ម (Pricanthusarenatus) ត្រីថ្លែនធំ (Saurida) ត្រីកូនគុំ (Atule) ត្រីកាវ៉ាវ ៦ប្រភេទ (6 species of Eleutheronema) ត្រីចេក (Seriola) និងត្រីពពៃ (Upeneus sulphureus) (រូបភាព៤,៥,៦,៧,៨,៩)។

*(នៅមានត)*

ដោយ ទូច ស៊ាងតាណា

## ១- ពន្យល់ពាក្យ

**សិល្បសាស្ត្រ**=គឺជាក្បួនរៀនចំណេះវិជ្ជាការមន្តអាគមផ្សេងៗ ហើយមាន ១៩យ៉ាង៖

១. សូតិ = ចំណេះអំពីសម្រែកសត្វ
២. សម្មតិ = ចំណេះអំពីកំណើតព្រៃភ្នំជាដើម
៣. សំខ្យា = ចំណេះអំពីលេខ
៤. យោធា = ចំណេះអំពីជំនាង
៥. នីតិ = ចំណេះអំពីល្បិចគ្រប់គ្រង
៦. វិសេរិកា = ចំណេះអំពីល្បិចចិញ្ចឹមជីវិត
៧. គណិកា = ចំណេះអំពីតារាវិទ្យា
៨. គន្ធព្វា = ចំណេះអំពីភ្លេង
៩. តិកិច្ឆា = ចំណេះអំពីពេទ្យ
១០. ធនពេធា = ចំណេះអំពីល្បិចបាញ់ធ្នូសរ
១១. បុរាណា = ចំណេះអំពីវត្ថុបុរាណ
១២. ភន្ទសា = ចំណេះអំពីកាព្យ
១៣. ជោតិសា = ចំណេះអំពីក្បួនហោរ
១៤. មាយា = ចំណេះអំពីត្បូង
១៥. ហេតុ = ចំណេះអំពីវិចារហេតុផល
១៦. វន្តុង្គា = ចំណេះអំពីល្បិចចិញ្ចឹមសត្វ និងដំណាំ
១៧. យុទ្ធសា = ចំណេះអំពីល្បិចចម្បាំង
១៨. ភាសណ្ឌា = ចំណេះអំពីសំនួនវោហារ
១៩. ឥតិហាសា = ចំណេះអំពីរបៀបរកទិសល្អ ពេលស៊ីបាយ

**នាដ្យរស** = រសឬតម្លៃនៃរបាំ អក្សរសិល្ប៍ ... ។
នាដ្យរស មាន ៩៖

១. សិង្ហារៈ = គួរស្រឡាញ់
២. ករុណាៈ = គួរស្តាយស្រណោះ
៣. វីរៈ = គួរកោតព្រោះក្លាហាន
៤. អព្ភុតៈ = គួរស្ញើច
៥. ហាស្យៈ = គួរសើច
៦. ភយានកៈ = គួរតក់ស្លុត
៧. សន្តៈ = គួរស្ងួតស្ងប់
៨. វិភច្ឆៈ = គួរស្អប់ខ្ពើម
៩. រុទ្ធៈ = គួរខឹងក្នាញ់

**នាថករណធម៌** = ធម៌ជាទីពឹងពំនាក់ ។
នាថករណធម៌ មាន ១០៖

១. សីល = រក្សាកាយវាចារឱ្យល្អបរិសុទ្ធប្រពៃ
២. ពាហុសច្ចៈ = មានចំណេះដឹងច្រើន
៣. កល្យាណមិត្តា = សេពគប់មនុស្សល្អ
៤. វចស្សតា = ងាយប្រដៅ
៥. ណីយេសុទក្ខតា = ឈ្លាសវៃក្នុងសេដ្ឋកិច្ច
៦. ធម្មកាមតា = ប៉ងប្រាថ្នាធម៌ល្អ
៧. វីរិយៈ = ព្យាយាមវៀរអំពើអាក្រក់ ហើយប្រព្រឹត្តតែអំពើល្អ
៨.សន្តោសៈ= ពេញចិត្តនឹងអ្វីជារបស់ខ្លួន
៩. សតិ = ចងចាំមិនភ្លេច
១០. បញ្ញា = ដឹងច្បាស់នូវគំនិត ។

## ២- ទំនោរធម្មជាតិមនុស្ស ( Tendance de la nature humaine )

### ក. និយមន័យ

ទំនោរគឺជាកម្លាំង ហើយជាកម្លាំងច្បាស់លាស់តម្រង់ទៅរកគោលបំណងត្រឹមត្រូវ។ តាមលោក បួលូ (Burloud) ទំនោរមានលក្ខណៈពីរយ៉ាងគឺ : សម្ទុះជំរុញ (impulsion) និងទិស (direction)។ដូចនេះ ទំនោរសំគាល់ការតម្រង់ទៅរកទិសសព្វយ៉ាងនៃសកម្មភាពជីវិត។និយាយយ៉ាងខ្លីទំនោរគឺការទោរទន់ ទៅរកឧត្តមគតិណាមួយ ប្រកបដោយបំណងនិងទិសត្រឹមត្រូវ ។ ឧទាហរណ៍ : ចំណាប់អារម្មណ៍របស់បុគ្គលទូទៅ ចំពោះសច្ចភាព កាមតណ្ហា វីរភាព ឬស្នាដៃណាមួយ សុទ្ធសឹងជានិមិត្តរូបនៃចំណូលចិត្តជំនក់អារម្មណ៍។បើកាលណាអារម្មណ៍នោះឯងវាជំពាក់ខ្លាំងដកពុំរួច ទើបកើតមានរូបភាព នៃកម្លាំងច្បាស់លាស់ ដែលបញ្ជាក់ថា នេះហើយជា « ទំនោរ »។ ទំនោរនេះបង្ហាញរូបច្បាស់ កាលណាអាកប្បកិរិយាខាងក្រៅ ធ្លាយចេញមកដោយទប់ពុំបាន។

### ខ. នានាភាពនៃទំនោរ

តាមពិតទំនោរមនុស្សចែកជាប្រាំកងធំៗគឺ :

ខ១. ទំនោរសរីរាង្គ (tendance organique) គឺជាទំនោរទាំងឡាយដែលកើតឡើងពីសរីរាង្គរបស់មនុស្សឬសត្វដែលជាភាវៈរស់។គេអាចសំគាល់ឃើញនូវទំនោរពីរបែបគឺ ៖

-សភាវគតិរក្សា (instinct de conservation) គឺជាការបង្ហាញទំនោរសំខាន់របស់ភាវៈរស់ ដែលចង់បន្តភាវៈខ្លួនទៅមុខទៀត ។

-ការស្រេកឃ្លាន (appétit) គឺជាទំនោរដែលមនុស្សនិងសត្វមានដូចគ្នា ប្លែកគ្នាតែត្រង់សរីរាង្គមនុស្សខុសពីសរីរាង្គសត្វ ហើយម្យ៉ាងទៀតការស្រេកឃ្លានរបស់មនុស្សឬសត្វ ទៅលើអាហារ ជាទំនោរជាក់លាក់ ប៉ុន្តែមានលក្ខណៈខុសគ្នា ។ ទំនោរមនុស្សទទួលឥទ្ធិពលសង្គម ដែលគេជឿថាមានលក្ខណៈសំខាន់បីគឺ៖

១-លក្ខណៈសង្គមកម្ម (socialisation)

២-លក្ខណៈស្មុគស្មាញ (complication)

-លក្ខណៈចិត្តកម្ម (spiritualisation)

រីឯទំនោរសត្វ គឺឥន្ទ្រិយារម្មណ៍ឃ្លាន និងទម្លាប់សុទ្ធសាធ។

ខ២. ទំនោរអន្តរបុគ្គល (tendance inter-individuelle) គឺជាទំនោរដែលកើតឡើងពីទំនាក់ទំនងរវាងញាណរបស់បុគ្គលម្នាក់ៗទៅនឹងញាណរបស់ជនដទៃ។ មនុស្សមានទំនោរអន្តរបុគ្គល ព្រោះមនុស្សមានទំនោរដែលមានលក្ខណៈប្លែកៗ កប់នៅក្នុងសរីរាង្គរបស់ខ្លួន។ទំនោរប្លែកៗទាំងឡាយដែលញ៉ាំងឱ្យមនុស្សមានទំនោរអន្តរបុគ្គលគឺ ៖

-សភាវគតិក្រុមនិងសមានចិត្តឆ្លង (instinct grégaire et sympathie-contagion)

-សភាវគតិពីកំណើត ដែលមនុស្សបានទទួលពីម្តាយរបស់ខ្លួន (instinct maternel)

-សមានចិត្តចូលគ្នារបស់មនុស្ស (sympathie communion)

-ទំនោរបរទត្ថភាព (tendance altruiste)

-ទំនោរអត្តទត្ថភាព (tendance égoïste)

ខ៣. ទំនោរសង្គម (tendance sociale) : គឺជាទំនោរដែលកើតមកពីកម្លាំងអនុស្សាវរីយ៍របស់មនុស្សពីកម្លាំងដែលកើតមានឡើងក្រោយពេលដែលមនុស្សនោះបានរួមរស់ជាមួយគ្រួសារនិងមាតុប្រទេសរបស់ខ្លួនអស់ពេលដ៏យូរ។ទំនោរសង្គមចែកចេញជាពីរគឺ ៖

-ទំនោរគ្រួសារ (tendance domestique oufamiliale) ដូចជាស្នេហារវាងប្រពន្ធប្តីស្នេហាម្តាយឪពុកនិងកូន ស្នេហារវាងបងប្អូនបង្កើត។ ទំនោរនេះបង្រួបបង្រួមសមាជិកទាំងឡាយ នៃគ្រួសារនីមួយៗ

-ទំនោរមាតុភូមិ (tendance patriotique) ដែលជំរុញពលរដ្ឋ ឱ្យស្រលាញ់ស្រុកកំណើតរបស់ខ្លួន ឱ្យជាប់ចិត្តនឹងប្រពៃណី ភាសាជាតិ ...។ ទំនោរនេះអាចជំរុញអ្នកស្នេហាជាតិ មាតុភូមិ ឱ្យធ្វើពលិកម្មយ៉ាងធំៗដើម្បីបម្រើនិងការពារមាតុប្រទេស។ទំនោរនេះខ្លាំងឬខ្សោយ មានឬពុំមាន វាអាស្រ័យនៅលើតម្លៃ នៃមនោគមវិជ្ជាជាតិ (idéologie nationale)

ដែលជាកត្តាមូលដ្ឋាននៃការអប់រំជាតិ។រីឯមនោគមវិជ្ជាជាតិ ក៏ពុំអាចកើតមានឯងៗដែរ គឺមហាវីរបុរសជាតិ ឬជាតិទាំងមូលនេះហើយ ដែលជាអ្នកខិតខំរាវរកប្រឌិតឡើងតាមតម្រូវការរបស់ប្រទេសនីមួយៗ។

សរុបសេចក្តីទៅ មនោគមវិជ្ជាជាតិជាមូលដ្ឋានចម្បងនៃការអប់រំ ហើយការអប់រំនេះដែលស្របទៅនឹងធម្មជាតិពិត ជីវិតពិត អនុវត្តន៍ពិត ប្រតិបត្តិពិត ជាកត្តាចាំបាច់បំផុតក្នុងការបណ្តុះសម្បជញ្ញៈជាតិ និងទំនោរស្នេហាមាតុប្រទេស។ ទំនោរសង្គមផ្តល់ផលប្រយោជន៍ដល់សង្គមជាតិ ដូចតទៅនេះ ៖

-ជំរុញពលរដ្ឋឱ្យស្រឡាញ់មាតុភូមិកំណើតរបស់ខ្លួន

-បង្កើតគំនិតស្រឡាញ់ប្រពៃណី និងជាតិរបស់ខ្លួន

-ជំរុញអ្នកស្នេហាមាតុប្រទេសឱ្យធ្វើពលីកម្មយ៉ាងធំ ដើម្បីបម្រើនិងការពារមាតុប្រទេស

-ទំនោរសង្គមអប់រំពលរដ្ឋ ឱ្យមានឧត្តមគតិជាតិច្បាស់លាស់

-បង្កើតមនោគមវិជ្ជាជាតិ ដែលជាកត្តាបញ្ជាក់ នូវមូលដ្ឋាននៃការអប់រំជាតិ

-ញាំងការអប់រំឱ្យស្របទៅតាមគោលអប់រំជាតិពិត ដើម្បីបណ្តុះសម្បជញ្ញៈជាតិ ។

២៤. ទំនោរឧត្តមគតិ (tendance idéale) គឺជាទំនោរ ដែលកើតពីកម្លាំងចិត្តរបស់មនុស្ស ក្រោយពីមានជំនក់ទៅលើតម្លៃផ្សេងៗរបស់អ្នកដទៃ។តំលៃដែលញាំងមនុស្សឱ្យមានទំនោរឧត្តមគតិគឺ ៖

-តំលៃសញ្ចេតនាក្នុងសាសនា (sentiment religieux)

-តំលៃសីលសញ្ចេតនា (sentiment moral)

-តំលៃសញ្ចេតនាសិល្បៈរស (sentiment esthétique)

-តំលៃសញ្ចេតនាបញ្ញា (sentiment intellectuel)

២៥. ទំនោរផ្ទាល់ខ្លួន (tendance personnelle) គឺជាទំនោរដែលមានលក្ខណៈជាបុគ្គលនិយម (individualisme) ឬអត្តទត្តនិយម។កម្លាំងដែលញាំងមនុស្សឱ្យមានទំនោរផ្ទាល់ខ្លួនមាន៤យ៉ាង :

-កម្លាំងដែលកើតពីសញ្ចេតនាលើសេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន (dignité personnelle)

-កម្លាំងដែលកើតពីតម្រូវការឯករាជ្យ (besoin d´indépendance)

-កម្លាំងដែលកើតពីអំណាចគ្រប់គ្រងត្រួតត្រា (besoin de domination)

-កម្លាំងដែលកើតពីអស្មិមានៈ (amour propre)

## គ. សន្និដ្ឋាន

សកម្មភាពរបស់មនុស្ស ទោះជាតាមផ្លូវចិត្តក៏ដោយ ផ្លូវកាយក៏ដោយ ផ្លូវបញ្ញាក៏ដោយ សុទ្ធតែមានបុព្វហេតុទាំងអស់។ ឯបុព្វហេតុទាំងនោះតែងតែជាប់នឹងទំនោររបស់មនុស្សជានិច្ច។ ឯទំនោរនេះទៀតខ្លះមានមកពីធម្មជាតិខ្លះបានមកពីការអប់រំ។តែចំពោះទំនោរធម្មជាតិរបស់មនុស្សតែងតែទទួលឥទ្ធិពលសង្គម។ម្ល៉ោះហើយដើម្បីយល់ទំនោរនេះគេត្រូវពិនិត្យ ឬសិក្សាសង្គមដែរ។ ដូចនេះបានជាគេសង្កេតឃើញសីលវិទូ (moraliste) តែងតែពឹងពាក់សង្គមវិទូនិងចិត្តវិទូ ដើម្បីទទួលបានពត៌មានផ្សេងៗព្រោះប្រភពនៃអំពើរបស់មនុស្ស ជាពិសេសអំពើសីលវិជ្ជានេះឯង តែងតែទាក់ទងនឹងឥទ្ធិពលសង្គម និងកម្លាំងចិត្តមនុស្ស។

**ក្រមសីលធម៌ និង គុណធម៌ នៃការរស់នៅ**

**បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង**

## ១- ឱ ! នេះឬមេផ្ទះ (បទពាក្យ៧)

សាច់អាំងបន្លែខជើងជ្រូក
មិនសូវហ៊ានលូកក្រែងឆាប់អស់
ដួសគ្រប់សម្រាំងមិនឱ្យខ្វោះ
ជូនទុកទាំងអស់ជូនស្វាមី ។
ចំពោះកូនៗក៏ដូចគ្នា
ចូលចិត្តយ៉ាងណាជូសាបប្រៃ
ឱ្យតែប្រាប់ម៉ែម៉ែលកលៃ
ចង់ឱ្យកូនថ្លៃធំធាត់ឆាប់ ។
ចំណែកខ្លួនម៉ែខ្លួនប្រពន្ធ
អ្នកអាចអត់ធន់មិនបាច់ប្រាប់
ផែប៉ូវប្រហុកមានស្រាប់ៗ
ម្ហូបច្រើនទើបចាប់ហូបតិចតួច ។
នេះជាធម្មតាចិត្តស្រីខ្មែរ
អបរំហូរហែឱ្យកាន់ក្ដួច
សុខទុក្ខប្ដីកូនគិតស្រាវស្រួច
គ្មានចិត្តលាក់លួចស្មោះស្មគ្រពិត ។
គំនិតនេះឃើញថាល្អហើយ
តែស្រីយើងអើយគួរតែគិត
ដល់ខ្លួនឯងផងទើបជីវិត
រស់រីករាយពិតផុតទុក្ខភ័យ ។
ត្រូវគិតថាខ្លួនជាមនុស្សដែរ
ហេតុអ្វីថ្នមថៃតែកូនប្ដី
សមាជិកគ្រួសារទោះប្រុសស្រី
តម្លៃនិងន័យស្មើៗគ្នា ។
ម្យ៉ាងទៀតនាងជាមេគ្រួសារ
សុខភាពគ្រឺថ្លាទើបធានា
ជ្រោងសមាជិកឱ្យក្លាយជា
ពលរដ្ឋថ្លៃថ្លាក្នុងសង្គម ។

ឱផ្កាពណ៌ស្វាយ (២០០៥)- អ្នកស្រី ស៊ឹម ចាន់យ៉ា

## ២- ចំណូលចិត្ត (បទពាក្យ៧)

បើលោកសម័យនិយមយល់
តម្កើងតម្កល់សម្ភារៈ
ហើយមនុស្សឈ្លោះគ្នាព្រោះវណ្ណៈ
បុណ្យសក្តិលុយកាក់សម្បត្តិទ្រព្យ។
កវីសូមឱ្យចេះខន្តី
មេត្តាប្រណីអ្នកចង់ស្ងប់
ទោះបីមាក់ងាយឬក៏ស្អប់
មិនភប់ប្រសប់តាមចិន្តា។
សូមតែទុកឱ្យគ្នាស្ងប់ចិត្ត
រស់តាមក្រមក្រឹត្យបុរាណា
តាមដោយតម្រាយពុទ្ធដីកា
លះបង់តណ្ហាំរំលត់ទុក្ខ។

## ១- រឿងដើមទៀបនិងដើមសេដា

កាលនោះមានលំនៅឋានមួយប្រកបទៅដោយរុក្ខជាតិចម្រុះស្រស់បំព្រង។នៅប្របរបងខាងមុខមានដើមទៀបមួយដើមដុះនៅក្បែរដើមសេដាមួយដើម។ ក្រោយមក ដើមសេដាលូតលាស់បានខ្ពស់បែកមែកសាខាមានផ្លែ រណោងរណោងជាច្រើនគួរឱ្យចង់គយគន់។

ថ្ងៃមួយដោយឃើញដើមសេដារីកធំធាត់លូតលាស់បានល្អ ដើមទៀបក៏សួរទៅកាន់ដើមសេដាថា៖ ហេតុអ្វីក៏បងមានដើមថ្លោស និងមានផ្លែច្រើនដូច្នេះ?

ដើមសេដាឆ្លើយតបទៅវិញថា៖ នេះមកពីខ្ញុំទទួលបានជីរជាតិនិងពន្លឺថ្ងៃបានគ្រប់គ្រាន់ល្មមទើបខ្ញុំដុះលូតលាស់បានលឿន។

ដើមសេដាសួរទៅដើមទៀបវិញថា៖ចុះហេតុដូចម្ដេច បានជាបងឯងបង់រូបបង់ឆោម ចេះតែស្វិតស្រពោនទៅៗ បើយើងដុះជិតគ្នាក្នុងទីតែមួយទេ?

ដើមទៀបឆ្លើយតបទៅដើមសេដាវិញថា៖ឱបងអើយ! ខ្ញុំក្លាយទៅជាស្គមកំព្រឹង គ្មានស្លឹកគ្មានផ្លែបែបនេះ ក៏មកពីខ្ញុំច្រណែននឹងបង ហើយខំប្រឹងលូតឱ្យខ្ពស់ជាងបងតែឥឡូវនេះខ្ញុំស្ទើរតែទប់ខ្លួនមិនជាប់ទៅហើយ។

ដើមសេដាក៏ពោលបន្តឡើងថា៖ ចិត្តប្រកួតប្រជែងមិនអាចខ្វះ ប៉ុន្តែអ្វីៗមិនគួរបង្ខំហួសមាឌនោះទេ។

ពេលក្រោយមកដើមទៀបក៏ក្លាយទៅជាក្រៀមស្វិតក្រញង់ រលួយគល់ដួលរលំមកលើដី។

## ២- រឿងឆ្មានិងកណ្ដុរ

គ្រាមួយនោះ មានសត្វកណ្ដុរមួយអើតក្បាលចេញពីរូងមក ឃើញសត្វឆ្មាមួយដើរមកជិត កណ្ដុរក៏ថយខ្លួនផុតពីក្រចកឆ្មា ហើយបាននិយាយបន្ទោសឆ្មាថា៖

ឯងនេះកាចសាហាវណាស់ អញនិងញាតិសន្ដានរបស់អញមិនដែលធ្វើអ្វីអាក្រក់ដល់ឯងសោះ ហេតុអ្វីក៏ឯងចេះតែចាប់សម្លាប់ពួកអញទាំងយប់ទាំងថ្ងៃ។

កណ្ដុរពោលបន្តទៀតថា៖ ចូរឯងដឹងថាអ្នកណាកាចសាហាវ អ្នកនោះត្រូវតែមានទោសជាដរាប បើចង់បានសេចក្ដីសុខត្រូវតែរៀនធ្វើអំពើល្អ។

ឆ្មាឮហើយរួសរាន់ឆ្លើយតបវិញថា៖ អើរុំ! ឯងនេះមានប្រាជ្ញាណាស់អានាង ដោយសារតែឯងបានជាអញដឹងថា ធ្វើអំពើល្អ ទើបបានសេចក្ដីសុខក្នុងលោកនេះ។ ដូច្នេះអញស្បថថា លែងធ្វើអំពើអាក្រក់ដល់ឯងទៀតហើយ មកណេ៎ះមកអានាង! មកកុំខ្លាចអញអី អញស្រឡាញ់ឯងណាស់។

កណ្ដុរបានឮសម្ដីឆ្មាដូច្នោះហើយ មានចិត្តត្រេកអរសប្បាយរីករាយយ៉ាងខ្លាំង វាចង់រត់ចេញមកលេងជាមួយនិងឆ្មា ដោយវានឹកស្មានថា បានសេចក្ដីសុខមែន។រំពេចនោះគ្រាន់តែកណ្ដុរអើតក្បាលចេញផុតពីរូងបានបន្តិច ឆ្មាក៏លោតទៅសង្គ្រប់ចាប់ខាំស៊ីបាត់ទៅ។



ប្រាសាទព្រះស្រី ឬប្រាសាទស្រី
ស្ថិតនៅក្នុងភូមិប្រាសាទ ឃុំដារ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង



ប្រាសាទសម្បូរព្រៃគុក
ស្ថិតនៅក្នុងភូមិសម្បូរ ឃុំសម្បូរ ស្រុកសម្បូរ ខេត្តកំពង់ធំ